# មជ្ឈមណ្ឌលឯកសារកម្ពុជា

សម្ភាសន៍ជាមួយឈ្មោះ ម៉ឹន វើត ភេទប្រុស អាយុ៥៦ឆ្នាំ

មុខងារសម័យខ្មែរក្រហមៈ អនុប្រធានមន្ទីរកងពល១១៧

ស្រុកកំណើតនៅភូមិក្បាលអូរ ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ

សព្វថ្ងៃរស់នៅភូមិទួល ឃុំបារាំងធ្លាក់ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង

ថ្ងៃទី១៣ ខែ សីហា ឆ្នាំ២០១៣

សម្ភាសន៍ដោយៈ ឡុង ដានី

០១:៣៦:៥៦

៤៩ទំព័រ

ដានីៈ ចឹងឈ្មោះលោកពូពេញឈ្មោះអីដែរ?

វើតៈ ឈ្មោះ ម៉ឹន វើត ។

ដានីៈ ម៉ឹន វើត!

វើតៈ ពីដើម សម័យពីណាពីណើមកដល់មកឈ្មោះទាហានរាល់ថ្ងៃដាក់ ម៉ឹង វើត ។

ដានីៈ ម៉ឹនវើត!

វើតៈ បាទ! ប្រែឈ្មោះ

ដានីៈ ចឹងប្រែឈ្មោះ ពេលណា?

វើតៈ ម៉ឹង ហ្នឹងមកកែ ឲ្យត្រូវក្របខ័ណ្ឌទាហានេះ គេដាក់គេភ្លេចអា«ឹ»ហ្នឹង ។

ដានីៈ ចឹងឥឡូវលោកពូដាក់ឈ្មោះ ម៉ឹង វើតវិញ?

វើតៈ បាទ ។

ដានីៈ អាយុប៉ុន្មានហើយពូ?

វើតៈ អាយុ៥៦ ហើយកើតឆ្នាំ៥៨ ។

ដានីៈ ហ៊ីកើតឆ្នាំ៥៨ណ៎ ។

ដានីៈ លោកពូស្រុកកំណើតកើតជានៅណាដែរ?

វើតៈ នៅភូមិក្បាលអូរ ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ ។

ដានីៈ ចឹងមានស្រុកកំណើតជាមួយអ៊ំ យុត?

វើតៈ បាទ ។

ដានីៈ ជាមួយយាយ ចែម ដែរ?

វើតៈ បាទ ។

ដានីៈ ចឹងអ៊ីស្គាល់តាំងពីក្មេងៗមកដែរអត់ទេ?

វើតៈ ខ្ញុំស្គាល់តាំងពីក្មេងៗដែរ ។

ដានីៈ ព្រោះអ្នកនៅក្បាលអូរសំបូរអ្នកតស៊ូ ដូចជាមានគណៈស្រុកច្រើនដែរ ដូចយាយបូរអីគាត់ នៅក្បាលអូរ យាយបូរ គណៈស្រុកកៀនស្វាយ ហើយគណៈស្រុកនៅខាងកោះធំស្អាងអី ។

វើតៈ ឈ្មោះ ប៉ក់ៗ ប៉ក់ ស្លាប់នៅនេះ យួនបាញ់ ជិះដីរ៉ែនៅរតនៈគិរី ។

ដានីៈ ហើយបងប្អូនគាត់២,៣នាក់ទៀតនោះ?

វើតៈ បងប្អូន ប៉ក់នៅ បងបឿន មិនដឹងនៅឯណាខ្លះទេ ។

ដានីៈ បាទៗ!

វើតៈ នៅប្រពន្ធដើមគាត់... ។

ដានីៈ ចឹងឪពុកលោកពូឈ្មោះអីដែរទៅ?

វើតៈ ឈុំ ដី ។

ដានីៈ ឈុំ ដី! មើលប្រវត្តិរូបនេះវិញទៅ ។

ដានីៈ បាទៗ! អត់អីទេ លោកចាំលោកពូប្រាប់ខ្ញុំក៏ល្អ ។

វើតៈ បាទ!

ដានីៈ សព្វថ្ងៃគាត់នៅរស់ ឬក៏ស្លាប់?

វើតៈ ស្លាប់! ស្លាប់តាំង៦៨,៦៧មក ។

ដានីៈ ម្ដាយ?

វើតៈ ញឹម រឿន! គាត់ស្លាប់ដែរ ។

ដានីៈ គាត់ស្លាប់ដែរ! គាត់ស្លាប់យូរហើយ?

វើតៈ ម្ដាយខ្ញុំ គាត់ស្លាប់ឆ្នាំ៧៩ ស្លាប់ក្រោយនេះទេ ។

ដានីៈ លោកពូមានបងប្អូនប៉ុន្មាននាក់ដែរ?

វើតៈ បងប្អូនបង្កើតនៅរាល់ថ្ងៃនៅពីរ ស្លាប់បង ។

ដានីៈ បងប្អូនទាំងអស់តែម្ដង មានប៉ុន្មាននាក់?

វើតៈ បីតែចាប់៧៨នេះមួយដែរ ។

ដានីៈ ចឹងបីនាក់ ។

វើតៈ បងនោះឪពុកផ្សេង ។

ដានី	បីនាក់ មានឪពុកផ្សេងម្នាក់?

វើត៖	ឪពុកផ្សេងបង ម៉ែខ្ញុំមេម៉ាយ ប៉ាខ្ញុំយក ។

ដានី៖	ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

វើត៖	ប្រុសទាំងបី ។

ដានី៖	ហ៊ូ! ប្រុសទាំងបី ។ ទី១បងគេ ឈ្មោះ?

វើត៖	ឈ្មោះ វឿន ។

ដានី៖	ឈ្មោះ វឿន?

វើត៖	បាទ!

ដានី៖	ឈ្មោះវឿន ដែលថាគេចាប់ទៅនៅឆ្នាំ៧៨?

វើត៖	បាទ!

ដានី៖	ចាប់ដោយសារតែមូលហេតុអីឆ្នាំ ៧៨?

វើត៖	គាត់ឡើងប្រធានវរៈបានប៉ុន្មានខែដែលហ្នឹង ពីមុននៅលង្វែក ដល់មកពោធិ៍ចិនតុងនៅកង រថក្រោះហ្នឹង គេចាប់បងវឿន រួចទៅចាប់បងខ្ញុំទៅ ។

ដានី៖	ចាប់ បងវឿន ណា?

វើត៖	បងវឿន ទៅពីខេត្តកំពតទៅ មិនទៅនៅកំពង់ចាមដែរ មេទ័ពអាហ្នឹងចាប់នៅឆ្នាំ៧៨ ជាមួយគ្នា ។

ដានី៖	ឈ្មោះ វឿន ហ្នឹងគាត់ទៅកំពង់ចាមជាមេទ័ពកងពលលេខប៉ុន្មាន?

វើត៖	អត់ទេ! ទៅពីកំពតទៅតំបន់ ទៅដល់កំពង់ចាមហ្នឹងគាត់នៅទ័ពខេត្តទ័ពតំបន់ មុនយួនចូល ចាប់ជាមួយគ្នាស្រករហ្នឹង ស្រករពូលាងស្រករអីហ្នឹង ស្រករគ្នាទាំងអស់ពីនេះទៅចាប់ទាំង អស់ ។

ដានី៖	ចឹងឈ្មោះ វឿន ហ្នឹង គាត់ចេញពីកំពតទៅកាន់ទ័ពនៅខេត្តកំពង់ចាម?

វើត៖	បាទ!

ដានី៖	នៅតំបន់ភូមិភាគកណ្ដាល?

វើត៖	បាទ!

ដានី៖	នៅភូមិភាគកណ្ដាល ឬគាត់ទៅតំបន់ជាមួយអ៊ឹយុត?

វើត៖	បាទ! ចាប់មកដែរ ។

ដានី៖	ចាប់ជាមួយគ្នា ប៉ុន្តែបងរបស់លោកពូគាត់នៅពោធិ៍ចិនតុងទេ?

វើតៈ នៅពោធិ៍ចិនតុងនេះ ចាប់នៅពោធិចិនតុងនេះ ចាប់អ៊ីណុះខ្សែស្រឡាយជាប់គ្នា រាប់អាន ដូចជាប៉ាៗខ្ញុំពីដើម ប៉ាគាត់មុនរាប់អានជាមួយពូរឿន មិនមែនរឿនទេ ពូរិន ទេប្រឡំ ។

ដានីៈ ចឹង រិន ទេ?

វើតៈ បាទ!

ដានីៈ ចឹងបងពូជាវរសេនាតូច ឬវរសេនាធំ?

វើតៈ វរសេនាតូច ។

ដានីៈ វរសេនាតូចគេចាប់ដែរ?

វើតៈ បាទ!

ដានីៈ ចុះទី២?

វើតៈ ប្អូនខ្ញុំរាល់ថ្ងៃនៅកាប៊ីន ។

ដានីៈ ចឹងលោកពូទី២?

វើតៈ បាទ!

ដានីៈ ទី៣ប្អូននៅកាប៊ីន គាត់ឈ្មោះអី?

វើតៈ ឈ្មោះ ភ័ព ។

ដានីៈ ចឹងលោកពូកាលពីក្មេងមានបាបរៀនសូត្រដល់ណាដែរ?

វើតៈ ខ្ញុំរៀនបានត្រឹមថ្នាក់ទី៩ ។

ដានីៈ ចេះអានសរសេរច្បាស់ទេ?

វើតៈ អាន! កាលហ្នឹងទើបតែអាសង់ហ្គុយ និងអាសង់សៀកុងភ្លិច(Accent( ´ ) ( ˆ )) ។ រដ្ឋប្រហារទៅឈប់រៀន ។

ដានីៈ ប៉ុន្តែអក្សរខ្មែរអីយើងអាចអានដាច់ទាំងអស់ អានសរសេរធម្មតា?

វើតៈ បាទ ។

ដានីៈ ហឺ! រៀនថ្នាក់ទី៩នៅសាលាណាទៅ?

វើតៈ កាលហ្នឹងសាលាវត្តអង្គបក្សី ឬអាចម៍កុក ។

ដានីៈ វត្តអង្គបក្សីនៅក្នុងភូមិក្បាលអូរដែរអត់ទេ?

វើតៈ អត់ទេ! នៅក្នុងភូមិអង្គក្រឡាញ់ ។

ដានីៈ ភូមិអង្គក្រឡាញ់ ឃុំជាងទងដែរ?

វើតៈ	បាទ! នៅជាប់ៗគ្នាដែរ ជាប់ម្ខាងវត្តរាល់ថ្ងៃ ដាក់វត្តអន្តបក្សីដែរហ្នឹង ចាស់ពីដើមហៅវត្តអាចម៍កុក នៅវត្តអន្តបក្សីដែរ, នេះៗយកល្អសរសេរតាមនេះក៏បាន ។

ដានីៈ	ចឹងលោកពូឈប់រៀននៅឆ្នាំណាទៅ?

វើតៈ	ឈប់រៀនកាលឆ្នាំរដ្ឋប្រហារហ្នឹង ។

ដានីៈ	ចឹងឆ្នាំ៧០តែម្តងឈប់រៀន?

វើតៈ	បាទ!

ដានីៈ	ឈប់រៀនទៅយើងធ្វើអីទៀតទៅ?

វើតៈ	ឈប់រៀន! ម្តាយខ្ញុំ គាត់មកចូលព្រៃ ។

ដានីៈ	ចឹងម្តាយលោកពូចូលតស៊ូដែរចឹង?

វើតៈ	បាទ! ខ្ញុំនៅជាមួយយាយនៅភូមិ ដល់ឆ្នាំ៧៣បានខ្ញុំចូលបដិវត្តន៍ ។

ដានីៈ	ចឹងលោកពូចុលបដិវត្តន៍ឆ្នាំ៧៣?

វើតៈ	បាទ! នេះប្រវត្តិរូបខ្ញុំ ។

ដានីៈ	នៅឆ្នាំ៧៣ មានមូលហេតុអីបានជាលោកពូចូលបដិវត្តន៍?

វើតៈ	កាលហ្នឹងចេះតែភ្ញាក់រលឹក កាលហ្នឹងវាយជាមួយទាហាន លន់ នល់ នោះ ធ្វើនិរសាវែកបាយអីចឹងទៅណាស់ ។

ដានីៈ	ពេលចូលដំបូងទៅនៅណាទៅ?

វើតៈ	ទៅនៅខាងអន្លុងវែងជ័យនោះ ចេញពីស្រុក ។

ដានីៈ	ចឹងឆ្នាំ៧៣យើងចេញទៅខាងអន្លុងវែងជ័យ?

វើតៈ	បាទ! ទៅនៅខាងភ្នំសែនហាន ។

ដានីៈ	នៅភ្នំសែនហាន ហ្នឹងជាកងទ័ពនៅខាងស្រុកអន្លុងវែងជ័យ?

វើតៈ	ខ្ញុំជានិរសាតំបន់១៦០ មន្ទីរនិរសាតំបន់ តា មុត ហ្នឹងដែរ កាលហ្នឹង តា មុត មិនទាន់រៀបទៅកងពលទេ នៅគណៈតំបន់ ។

ដានីៈ	ចឹងលោកពូទៅភ្នំសែនហានហ្នឹង កងទ័ពតំបន់លេខប៉ុន្មាន?

វើតៈ	តំបន់១៣ ។

ដានីៈ	តា មុត ហ្នឹងគាត់ធ្វើជា?

វើតៈ	គណៈតំបន់១៣ ។

ដានីៈ	គណៈតំបន់មាន តា មុត?

វើត: មាន តា មុត , មាន តា សោម ។

ដានី: មានតែពីរនាក់ហ្នឹងទេ?

វើត: អត់ទេ មានក្រោមៗទៀត តែចាប់អស់ហើយ?

ដានី: ពីណាគេ?

វើត: មានក្រោមទៀត មាន ដែន ដែនមកមានចាប់ពីរមាន បង មុ៉យ មានណាបីប្អូននាក់នោះ បង និត អីគេចាប់អស់ហើយ ហ្នឹងប្អូនតា មុ៉ក ហើយហ្នឹង ។

ដានី: ឈ្មោះ អីគេ?

វើត: ឈ្មោះ និត សមាជិកគេចាប់ហើយនៅស្រុកអន្លង់វែង និត ហ្នឹងប្អូនតា មុ៉ក បង្កើត ។

ដានី: ប្អូនបង្កើត ឬប្អូនថ្លៃ?

វើត: ប្អូនបង្កើត ។

ដានី: ចឹងប្អូនតា មុ៉ក មានឈ្មោះ និត ដែរចឹង?

វើត: បាទ!

ដានី: ចុះពូ! តា សោម គាត់ជាអ្នកស្រុកណាដែរ?

វើត: តា សោម គាត់អ្នកកាសែត ជាអ្នកចាងហ្វាងកាសែត គាត់អ្នកស្វាយរៀងមិនដឹងព្រៃវែង មិនដឹងទេស្រុកកំណើតគាត់ ស្រុកកំណើតគាត់នេះខ្សែខាងប្ដីយាយមុន ។

ដានី: ហ្ន៎! នៅខាងព្រៃវែង?

វើត: គាត់ជាចាងហ្វាងកាសែតជាមួយហ្នឹងណា ។

ដានី: ដល់ពេលចឹងទៅ តា សោម គេចាប់គាត់ដែរ ឬអត់ដឹងទេ?

វើត: តា សោម ខ្ញុំអត់ដឹងទេ ព្រោះបែក កាលពីជំនាន់ហ្នឹងគេដកគាត់ពីគណៈតំបន់គាត់ឈឺគាត់កើតរោគស្ងួត កើតរោគស្ងួតដកគាត់ ព្រោះខ្ញុំទៅនៅទ័ពខាងគិរីវង្សទៅគាត់នៅតំបន់ដល់គាត់ឈឺគេដកគាត់មកព្យាបាល ដល់ព្យាបាល គាត់ដកមកនៅកន្លែងប១កន្លែងភ្លៀវណាដកមកហ្នឹងជាមួយ បង ឈាន នេះ ។

ដានី: ជាមួយ អ៊ុី ឈាន?

វើត: បាទ! ដកមកនៅហ្នឹងដល់រត់មកមិនដឹងជាបែកនៅណា ។

ដានី: អ៊ុី ឈាន គាត់នៅតាកែវដែរ?

វើត: អត់ទេ អ្នកព្រះវិហារ អ៊ុី ឈាន តែគាត់នៅជាមួយ តា អៀង សារី នៅក្រសួងការបរទេស ។

ដានី៖ ដល់ពេលគេដក តា សោម មកពីណាគេទៅគណៈតំបន់ជំនួស?

វើត៖ គណៈតំបន់ជំនួស តា សោម ឈ្មោះ ជឿន ។

ដានី៖ ចឹងឈ្មោះ ជឿន?

វើត៖ បាទ! ឈ្មោះ ជឿន ហ្នឹង ចាប់ដែរ ហ្នឹងពូខ្ញុំជីដូនមួយត្រូវជាអ្នកបីងព្រៃ សាច់ឈាមខាង តា ហ្នឹង ។

ដានី៖ ខាងតា ម៉ុក ដែរ?

វើត៖ បាទ!

ដានី៖ ចឹងយ៉ាងម៉េចបានចាប់សាច់ឈាមខាង តា ម៉ុក ដែរ?

វើត៖ ថាអត់មានទេ តក្មា ។

ដានី៖ ចាប់តក្មា តា សោម គាត់ ជឿន ហ្នឹងគាត់ទៅជំនួស?

វើត៖ ជឿន ហ្នឹង កាលពីមុនគាត់ជាគណៈស្រុកអន្លង់វែងដល់ហើយគាត់ឡើងមកតំបន់ ព្រោះ តា សោម ដក តា មុត គាត់ឡើងទៅកាន់កងពលហើយ ដល់ចឹងជឿន បានដកជឿន ចេញពី អាហ្នឹងខ្ញុំអត់ដឹងទៀត អ្នកក្រោយអត់ដឹងទេ ជឿនហ្នឹងដកទៅក្រសួងឧស្សាហ៍កម្ម ជាមួយ វន វើត ។

ដានី៖ ឆ្នាណាទៅ?

វើត៖ ឆ្នាំ៧៧ ។

ដានី៖ ចឹង តា សោម គេដកតាំងពីឆ្នាំណា?

វើត៖ តា សោម ដក៧៧ដែលហ្នឹង ។

ដានី៖ ចឹង តា សោម ដកឆ្នាំ៧៧ តា ជឿន ហ្នឹងគាត់មកកាន់តែមួយរយៈទេ?

វើត៖ កាន់តែមួយរយៈខ្លីទេ បានដកមកភ្នំពេញចាប់ ក្រោយមកខ្ញុំទៅក្រចេះ ឮថាចាប់ដែរ ។

ដានី៖ ចឹងជំបូងពូនៅខាងភ្នំសែនហាន?

វើត៖ បាទ! ឆ្នាំ៧៣-៧៤និង៧៥ហ្នឹងហើយ ។

ដានី៖ ហ្នឹង តា មុត គាត់ជាអ្នកគ្រប់គ្រងផ្ទាល់?

វើត៖ អាហ្នឹងខ្ញុំមន្ទីរ១៦០ហ្នឹង តា ជឿន មិញនេះ គាត់ឡើងគណៈតំបន់ គាត់កាន់ស្រុកអន្លង់ ជ័យផង គាត់ទទួលប្រធានយុវជនតំបន់ ហៅថាប្រធានយុវជនតំបន់ហ្នឹង... ។

ដានី៖ ចឹងស្រុកអន្លង់ជ័យហ្នឹងមិនមែនយាយ ចែម គាត់កាន់នៅហ្នឹង?

វើត៖ យាយ ចែម គាត់ជានារីតំបន់ គាត់គ្រាន់នៅក្នុងស្រុកតែគាត់នារីតំបន់ផ្សេងទៀត ។

ដានី:	គាត់គ្រប់គ្រងនារីតំបន់១៣ហ្នឹង?

វើត:	បាទ!

ដានី:	ប៉ុន្តែ យាយ ថែម គាត់នៅអន្លុងវែងដែរអត់?

វើត:	យាយ ថែម នៅអន្លុងវែងដែរ នៅជាមួយ តា ញ៉ែន តា ញ៉ែន គាត់ខាងស្រុកផ្ទាល់ ហើយបាន ពូ ជឿន ប្រធានយុវជនតំបន់តែគ្រប់គ្រងអន្លុងវែងជាមួយតាញ៉ែនហ្នឹងដែរ ។

ដានី:	ចឹងពូនៅភ្នំសែនហានហ្នឹងពី៧៣ ដល់៧៥?

វើត:	បាទ!

ដានី:	ចឹងតា មុត គាត់ចេញពីហ្នឹងទៀត ឬមួយអត់ទេ?

វើត:	គាត់ទៅនៅកំពង់សោមនោះ ។

ដានី:	ចឹងមុន៧៥គាត់មានបង្កើតកងពលទៀតទេ?

វើត:	គាត់បង្កើតកងពលទី៣ហ្នឹង មុន៧៥ ។

ដានី:	ចឹងលោកពូមានចូលក្នុងកងពលទី៣ទេ?

វើត:	អត់ទេ! ខ្ញុំនៅតំបន់ ។

ដានី:	ចឹងដាច់ពីគាត់?

វើត:	ដាច់ពីគាត់ ខ្ញុំនៅមិនបានមួយឆ្នាំផងទេ ខ្ញុំដាច់ពីគាត់ គាត់ឡើងកងពលផុតទៅ ខ្ញុំនៅនិរសា តំបន់ដដែល ។

ដានី:	ចឹងលោកនៅនិរសារបស់តំបន់?

វើត:	និរសារបស់ ជឿន ហ្នឹង

ដានី:	ម៉េចទៀតទៅលោកពូ?

វើត:	ដល់ហើយឆ្នាំ៧៥ ខែ៩ខ្ញុំទៅគិរីវង្ស ។

ដានី:	ចឹងចេញពីហ្នឹងទៅគិរីវង្ស?

វើត:	បាទ!

ដានី:	ចឹងចេញពីអន្លុងវែងទៅ?

វើត:	បាទ!

ដានី:	ពេលទៅគិរីវង្សទៅនៅកន្លែងណាទៅ?

វើត:	នៅកន្លែងកងពល នៅមន្ទីរកងពល ។

ដានី:	ចឹងនៅភូមិភាគនិរតីមានកងពលដែរ?

វើត:	មាន!

ដានី:	កងពលលេខប៉ុន្មានទៅ?

វើត:	កងពលទី២ហ្នឹង   ដល់រៀបក្រោយមករៀប២៥០ទៀត   ពីមុន៧៥ហ្នឹងមិនទាន់មានកងពលទេ ដល់៧៥បានរៀបមកងពលមានកងពលទី២តែមួយហ្នឹងដដែលទេ ពូវ៉ែន គ្រប់គ្រងដដែលគ្រាន់តែវាមានវរសេនាធំតំបន់១៣  មានវរៈសេនាធំខាងកំពត ដល់ក្រោយមកចូល ២៣០, ២១០, ២៧០, ២៥០ គេរៀបក្រោយនេះ ៤ហ្នឹង។

ដានី:	វ៉ែន ភូមិភាគនិរតីមានតែកងពលមួយទេ?

វើត:	មានកងពលទី២មួយទេ។

ដានី:	កងពលទី២ឈ្មោះ វ៉ែន កូនប្រសា តា ម៉ុក ហ្នឹង?

វើត:	បាទ! កូនប្រសារតា សាច់ឈាមខាង អ៊ឹ មុត ដែរ។

ដានី:	ចឹងឈ្មោះ ទឹម វ៉ែន បងគាត់ឈ្មោះ សេង ហ្នឹង?

វើត:	បាទ! សេង ស្លាប់បាត់ហើយ។

ដានី:	ចឹងកាលហ្នឹងមានវរសេនាធំប៉ុន្មានទៅ?

វើត:	នៅកងពលខ្ញុំហ្នឹង?

ដានី:	បាទ! កងពលទី២ហ្នឹង?

វើត:	កងពលទី២វាមានច្រើនណាស់  នៅអង្គរបុរី  នៅខាងកំពត២៣០អី  ខ្ញុំអត់ស្គាល់ទេ  ខ្ញុំដឹងតែប្រកខ្ញុំនៅហ្នឹង  មានតែគេហៅ១៧ហៅ១៥ហៅ១៦និង១៨  រៀបក្រោយចូល២៥០ ហើយហ្នឹង ខាង បង ភា គាត់គ្រប់គ្រងវិញហើយ។

ដានី:	១៥,១៦?

វើត:	បាទ!

ដានី:	ហ្នឹងដឹងថានៅគិរីវង្សទេ?

វើត:	ពីទល់មុខត្រឹមស្ពានដែកមកទល់នឹងកំពត អាហ្នឹងខាង២៥០។

ដានី:	កងពល២៥០?

វើត:	បាទ! អាហ្នឹងកងពលរៀបក្រោយនេះ។

ដានី:	ចឹងតាំងពី៧៥មកមានតែកងពលទី២មួយទេ?

វើត:	បាទ!មានកងពលទី២មួយទេ ខ្ញុំនៅក្នុងតំបន់នៅឡើយទេ។

ដានី:	ចឹងដល់ពេលណាឆ្នាំណាបានគេបង្កើតកងពល២៥០?

វើត៖ កងពល២៥០រៀបក្រោយហ្នឹង ខ្ញុំទៅក្រចេះផុតហើយ ខ្ញុំមកលេងម្ដងបានរៀបចំកងពលហ្នឹង អាចថា រៀបឆ្នាំ៧៦អីហ្នឹង ។

ដានី៖ អាច៧៦ ចុះលោកពូទៅក្រចេះឆ្នាំ៧៧ហ្នឹង?

វើត៖ រៀបមុននឹងបន្តិច តែគ្រាន់ខ្ញុំមិនបានទៅ ព្រោះបង ឆាវ កាលហ្នុងគាត់ដកមកពីវរសេនាធំ១១នៅទល់អន្លង់វុរីយើងនេះ ។

ដានី៖ កងពល២៥០ហ្នឹងពីណាធ្វើប្រធាន?

វើត៖ បង ភា ។

ដានី៖ ឈ្មោះ ភា! កងពល២៥០ហ្នឹងប្រចាំការនៅឯណា?

វើត៖ កន្លែងមន្ទីរកងពលនៅគិរីវង្សមួយកន្លែង មួយកន្លែងទៀតនៅភ្នំតាញោមមួយកន្លែងនៅជិតវត្តសោម ។

ដានី៖ កងពលនៅគិរីវង្សទាំងអស់?

វើត៖ ហ្នឹងហើយនៅជួរមុខគេអូរនៅភ្នំព្រះស្បរហ្នឹងមួយកន្លែងនៅក្រោយមន្ទីរពេទ្យអាសាលាកាឡេសក្រោយចេះ ។

ដានី៖ លោកពូអត់ដឹងថា កងពលទី២មានប៉ុន្មានវរសេនាធំទេ?

វើត៖ អត់ដឹង ។

ដានី៖ អនុ តា វ៉ែន ពីណាគេ?

វើត៖ អនុតា វ៉ែន កាលហ្នុងរៀបទៅមានបង ឈៀង តែឈៀង ស្លាប់បាត់ហើយ រៀបទៅបូព៌ាហើយហ្នឹង ខ្ញុំម៉េចដឹង ខ្ញុំដឹងតែកន្លែងខ្ញុំដែលខ្ញុំនៅ ។

ដានី៖ ចុះកូនប្រសារ តា ម៉ុក មួយទៀតឈ្មោះ បូ រ៉ាន?

វើត៖ ពូ បូរ រ៉ាន គាត់ខាងនេះផ្សេង គាត់នៅខាងអាឈើ អាអីផ្សេងគាត់នៅក្រោយ ។

ដានី៖ តែក្រោយមកគាត់មានឡើងកងទ័ពដែលអត់?

វើត៖ ក្រោយមកដូចជាអត់មានទេ នៅជាប់គារហូតមក ទើបមកឡើងយើងរត់យួននេះគាត់គ្រប់គ្រងនារីដឹកជញ្ជូនណា ដល់យួនកន្ត្រាក់មីនស្លាប់ទៅ ។

ដានី៖ ចឹងពូថា ពីខែ៩ឆ្នាំ៧៥ពូផ្លាស់ពីអន្លង់ជ័យទៅគិរីវង្ស ទៅគិរីវង្សទៅក្នុងមន្ទីរតំបន់?

វើត៖ កាលហ្នឹងទៅមន្ទីរតំបន់នៅក្នុងនិរសាដដែលទេ តែគ្រាន់ថាបានជាមេក្រុមនៅក្នុងមន្ទីរហ្នឹងខ្ញុំមានសិទ្ធចាត់ចែងរត់សំបុត្រស្នាមពីមេមកចឹងណា ។

ដានី៖ មន្ទីរតំបន់ហ្នឹងតំបន់១៣ហ្នឹង?

វើតៈ បាទ! និរសានៅកន្ទ័ពវិញហើយ ដល់អីចឹងខ្ញុំចេញផុតពីតំបន់មកនៅកន្ទ័ពវិញហើយ ។

ដានីៈ កន្ទ័ពរបស់តំបន់?

វើតៈ បាទ!របស់តំបន់ ។

ដានីៈ អាហ្នឹងជាវរសេនាធំ?

វើតៈ វរសេនាធំ ។

ដានីៈ គេហៅវរសេនាធំលេខប៉ុន្មាន?

វើតៈ វរសេនាធំកាលហ្នុងមិនទាន់មានលេខផង ហៅវរសេនាធំតំបន់ហ្នឹងបណ្តោយ ។

ដានីៈ ពីណាគេប្រធានតំបន់១៣កាលហ្នឹង?

វើតៈ កាលហ្នុងបង ផន ។

ដានីៈ ផន ដែលដកមកហ្នឹង?

វើតៈ មិនមែនទេ ផន ហ្នឹងទេ ផន នេះដកមកពីពាយ័ព្យមួយរយៈដកទៅវិញ គេចាប់ដែរ ។

ដានីៈ ផន ហ្នឹងគាត់នៅទេ?

វើតៈ អត់ទេ គេចាប់ដែរ ។

ដានីៈ លោកពូនៅនិរសារបស់ ផន ហ្នឹង?

វើតៈ បាទ! ដឹងថា ចាប់ ផន ហ្នឹងពូខ្ញុំយកខ្ញុំពីហ្នឹងទៅ ដឹងថាចាប់នេះ បានហៅទៅលេងក្រចេះ ទៅហ្នឹងក៏នៅហ្នុងបណ្តោយ ។

ដានីៈ លោកពូ! តំបន់១៣មានប៉ុន្មានស្រុកទៅ?

វើតៈ អាហ្នឹងពាល់រាប់តាមលេខណ៎ ។

ដានីៈ បាទ! រាប់តាមលេខក៏បានដែរ ។

វើតៈ មាន១០៥មាន១០៦មាន១០៧មាន១០៨ មាន១០៩ ។

ដានីៈ ១០៥,១០៦,១០៧,១០៨,១០៩ ។

ដានីៈ មានតែប៉ុណ្ណឹងទេស្រុក?

វើតៈ មានតែប៉ុណ្ណឹងទេ ១០៦ អង្គរជ័យ,១០៥ត្រាំកក់, ១០៩គិរីវង្ស, ១០៧ទ្រាំង, កោះអណ្តែត១០៨ មានប៉ុណ្ណឹងស្រុកទេ កាលហ្នឹងគាត់ព្រែកប្បាសចេញ កាត់សំរោងចេញ...។

ដានីៈ ប៉ុន្តែឃើញតែ១០៥នេះ ។

វើតៈ តាមតែខ្ញុំដឹង ។

ដានី:	គណៈស្រុកត្រាំកក់ពីណាគេ១០៥?

វើត:	កាលហ្នឹង ពូ ជឹម ដឹងកាលពីខ្ញុំនៅតូចៗខ្ញុំនៅរត់សំបុត្រអីហ្នឹង ។

ដានី:	អង្គុរជ័យ?

វើត:	អង្គុរជ័យ តាញៀនជាមួយយាយថែម ។

ដានី:	ទ្រាំង?

វើត:	ទ្រាំងខ្ញុំមិនសូវដឹងដែរ កាលជំនាន់ លន់ នល់ ខ្ញុំនៅរែកបាយ ។

ដានី:	ចឹងខាងកោះអណ្តែត?

វើត:	កោះអណ្តែត តា សៀង ហ្នឹងស្គាល់ធ្លាប់ដឹង កាលប្រជុំនៅភ្នំត្រែលញឹកណា ។

ដានី:	គេផ្លាស់មកស៊ឹងត្រែងដែរ?

វើត:	អត់ទេ! ភ្នំត្រែល វត្តភ្នំត្រែលនៅតានីហ្នឹង ហ្នឹងកន្លែងហ្នឹងមន្ទីរសិល្បៈ គេហៅសន្និបាតអីស្រុកអី, តំបន់អី ។

ដានី:	ហើយគិរីវង្ស?

វើត:	គិរីវង្សមាន តាតែម ហៅ តុំ ចាប់ដែរ ។ តា តុំ ខ្សែស្រឡាយជីដូនមួយយាយដែរ គេចាប់ទាំងអស់ហ្នឹង ។

ដានី:	ដល់គេចាប់ទៅដាក់ពីណាគេទៅជំនួសទៅ?

វើត:	គេចាប់ក្រោយមកខ្ញុំអត់ដឹងដែរ ខ្ញុំចេញទៅក្រចេះហើយ ។

ដានី:	ហើយគណៈតំបន់ដំបូង តា សោម?

វើត:	បាទ!

ដានី:	តា សោម ហើយមានពីណាទៀតទៅ?

វើត:	តា មុត, តា ដែន, តា ម៉ូយ, ភ្លេចអស់ហើយកាលហ្នុង ។

ដានី:	តែយាយ ថែម គាត់ខាងនារី?

វើត:	ខាងនារីតំបន់ ។

ដានី:	តែគាត់នៅក្នុងគណៈកម្មាធិការរបស់គេ?

វើត:	គណៈកម្មាធិការតំបន់ហ្នឹង ។

ដានី:	ទ្រាំងពូអត់ស្គាល់ទេ?

វើត:	អត់ស្គាល់ទេ ។

ដានី:	ហើយទទួលខាងយោធាតំបន់១៣ឈ្មោះ?

វើត: ពីដើមវាដកអីចេះ ចង់និយាយកាលពីដើមឡើយតា ណាំ គាត់តំបន់ហើយណាគាត់យោធាតំបន់តា ណាំ កាលជំនាន់វាយ លន់ នល់ ណាស់ តា ណាំ គាត់តំបន់ហ្នឹងហើយ ដល់ពេលតា ណាំ គាត់ជាប់ពាក់ព័ន្ធហ្នឹងហាណូយ គាត់មកពីវៀតណាម ដកគាត់ទៅបានបង ផន ហ្នឹងឡើង កាលដំបូងដើមនោះ តា ណាំៗ ប៉ុនគេចាប់ដែរហ្នឹង ។

ដានី: តា ផន ហ្នឹងឡើងក្រោយពេលឆ្នាំ៧៥រំដោះហើយ?

វើត: ឡើងក្រោយហ្នឹងទេ តាណាំ ដកភារកិច្ច អត់ចាប់ទេ គាត់ហាណូយគាត់និយាយប៉ៃឡាំៗ ហើយប្រពន្ធគាត់ហ្នឹងនារីតំបន់ដែរ ប្រពន្ធគាត់នៅគិរីវង្សហ្នឹងនារីតំបន់យាយ យឿន នោះ ដល់អីចឹងទៅដកភារកិច្ចគាត់ទៅវាពាក់ព័ន្ធជាមួយយាយ យឿន ។

ដានី: ហើយលោកពូទៅនៅខាងគិរីវង្សហ្នឹងពីខែ៩រហូតដល់...?

វើត: រហូតដល់ខែ៣ឆ្នាំ៧៧ ។

ដានី: យោធាយើងនៅគិរីវង្សហ្នឹងធ្វើអីខ្លះទៅ?

វើត: ខ្ញុំមានអីដឹកជញ្ជូនអ្នករបួសអីនាយអាយ បើកឡានដូនរបួសមកពេទ្យ ។

ដានី: គ្រាន់តែបើកឡានដូន?

វើត: គ្រាន់តែរត់សំបុត្រ ភាគច្រើនមិនសូវសំបុត្រទេ ច្រើនដឹកជញ្ជូនអ្នករបួស កាលហ្នឹងរបួសវាយជាមួយយួនញឹកណាំ! ឡានខ្ញុំហ្នឹងជាចាំបាច់ជាប់ជាមួយមន្ទីរពេទ្យហ្នឹងដូចថាយើងនៅក្នុងមន្ទីរកងពលត្រូវគ្រប់គ្រងមន្ទីរពេទ្យហ្នឹងណាស់ អីចឹងមានរបួសធ្ងន់ៗយើងបញ្ជូនមកខេត្តតាកែវអីចឹងមក មកបានចេញចូលនៅតាកែវទៀត...។

ដានី: តាកែវ! មន្ទីរភូមិភាគនៅតាកែវ?

វើត: កន្លែង តា នៅផ្ទះទឹកគាត់ហ្នឹង តែសាលាប្រជុំរបស់តានៅកន្លែងមុខទឹកហ្នឹង មន្ទីរពេទ្យផ្សេង មន្ទីរពេទ្យនៅកន្លែងដដែលហ្នឹង ។

ដានី: ភូមិភាគ តា គាត់គ្រប់គ្រងទូទៅ?

វើត: បាទ!

ដានី: បន្ទាប់ពីតា មកមានពីណាគេទៀត?

វើត: មាន តា សំ ប៊ិត គាត់ស្លាប់ហើយ ។

ដានី: សំ ប៊ិត មានតែពីរនាក់ហ្នឹងទេ?

វើត: មានពីរនាក់ ។

ដានី: មានសមាជិក មានអីទៀតទេ?

វើតៈ	សមាជិកអចិន្ត្រៃយ៍ តាមតំបន់មួយៗ នេះតាមខ្ញុំដឹងទេណា តំបន់មួយៗដូចជាលេខាតំបន់ មានជាប់ដើងភូមិភាគ ។

ដានីៈ	តំបន់១៣ តំបន់៣៥ តំបន់៣២ ហ្ន៎តំបន់៣៣ កាលហ្នឹងមានតែបីតំបន់និងទេ?

វើតៈ	បាទ! មានតែបីហ្នឹងទេ ។

ដានីៈ	ហើយតំបន់៣៥ពីណាគេជាប្រធាន?

វើតៈ	តំបន់៣៥កង ចាប, យាយ គាត់អនុទេ យាយគាត់ជាតំណាងរាស្ត្រទេ ។

ដានីៈ	យាយណា?

វើតៈ	យាយអួនឯងសម្អាសន៍មិញហ្នឹង ។

ដានីៈ	ហើយ៣៣មានពីណាគេ?

វើតៈ	៣៣ ខេង គេចាប់ដែរ ។

ដានីៈ	ឈ្មោះអី?

វើតៈ	ខេង ចាប់ពូខេងហ្នឹងទៅ ដាក់បងអុន បងអុនហ្នឹងចាប់ទៀត ដឹងឯណាឯណីទេ ៣៣ហ្នឹង រញ៉េរញ៉ៃណាស់ ។ ខ្ញុំនៅតូចៗ មកវាយខាងលិចភ្នំពេញនេះ រត់ទៅវិញមានបាយហូប ណាហូបតែពោតឆ្នាំ៧៤ មកនៅហ្នឹងអត់ចុះ ពួកខ្ញុំពី១៣មកវែកបាយ គេអត់ឲ្យបាយហូប វែកបាយហើយរត់ទៅវិញ អត់បាយដូចតែយើង... ។

ដានីៈ	បាទ! នៅ៣៥ កង ចាប ពីណាទៀតបន្ទាប់ពី?

វើតៈ	អត់សូវស្គាល់ទេហ្នុងនោះ ស្គាល់តែពូ រិន ស្គាល់អី រិន គេចាប់ដែរហ្នុង ។

ដានីៈ	ពូអីចឹងនៅតាកែវ ពេលហ្នុងមានវាយជាមួយយួនដែរអត់ ពេលដែលកងទ័ព...?

វើតៈ	ខ្ញុំដឹងតែវាយ លន់ នល់ ដល់ឈ្នះ លន់ នល់ ទៅនៅគិរីវង្ស អាហ្នឹងយួនប៉ះទង្គិចខ្លះ ។

ដានីៈ	យួនវាចូលមកដីយើងឈ្លានពានយើង ឬមួយយ៉ាងម៉េច?

វើតៈ	យើងនៅព្រំដែន ព្រែកអស់ហ្នឹង ពីដើមព្រំដែនមានព្រែកយើងនៅខាងលិចព្រែក វានៅ ខាងកើតព្រែកអីចឹងទៅ ប៉ុនដល់មកបុកខ្លាំងឆ្នាំ៧៧ ដែលខ្ញុំនៅក្រចេះហ្នឹង វាថាខាងហ្នឹង ក៏បុក ខាងក្រចេះក៏បុក ខ្ញុំមកដល់ស្នួល យួនបុកមកដល់ចម្ការកៅស៊ូស្នួលបាត់ហើយហ្នឹង ។

ដានីៈ	ពីឆ្នាំ៧៥ដល់៧៦អីហ្នឹងអត់មានវាយអីទេ?

វើតៈ	ឆ្នាំ៧៦អត់មានទេ ។

ដានីៈ	នៅខាងគិរីវង្សអត់មានទេ?

វើតៈ	អត់មានវាយទេ ។

ដានី៖ គឺរីវង្សហ្នឹងឈ្មោះ តែម ហៅ គុំ ហ្នឹង ជាគណៈស្រុក ឬក៏មានដូរថ្មីមកពេល...?

វើត៖ កាលខ្ញុំនៅមិនទាន់ដូរទេ ដល់ខ្ញុំទៅក្របេះបាត់បានឮថាចាប់ដែរ គាត់ទាក់ទងយួនថាអីហ្នឹង ណា ។ អាហ្នឹងជំនិត តា ដែលរត់លូនអីនាំតាចូលព្រៃអី គាគុំ ហ្នឹងឯងអ្នកនាំ ។

ដានី៖ ចុះមិញថា ប្អូន តា ម៉ុក ដែលគេចាប់នៅខាងអន្លុងវែង?

វើត៖ អត់ចាប់ទេ! តា និត មានចាប់ណា តា និត អាចនៅអន្លង់វែង ឬនៅស្រុកកំណើត បើ តា សាន ប្អូនថ្លៃ ។

ដានី៖ តា សាន ប្អូនថ្លៃ គាត់ធ្វើគណៈស្រុកនៅណា?

វើត៖ តា សាន ពីមុនគាត់នៅត្រាំកក់ ដល់ដកពួ ជីមទៅ, តា សាន ហ្នឹងហើយ ។

ដានី៖ ឥឡូវគាត់នៅ?

វើត៖ មិនដឹងថា គាត់នៅអន្លង់វែង ឬមួយនៅណា ។

ដានី៖ និត ហ្នឹងគាត់ជាគណៈស្រុកនៅណា?

វើត៖ និត ពីដើមគាត់ជាសមាជិកស្រុកនៅអន្លុងវែង ដល់ក្រោយមកឮថាឡើង ដកពួ ជឿន ទៅ ឮថាគាត់ឡើងតំបន់មួយរយៈហ្នឹង ខ្ញុំអត់ដឹងដែលគ្រាន់តែឮតៗទេណា អាចគាត់ឡើងតំបន់ មួយរយៈទៅ យួនចូលទៅក៏មិនដឹង ខ្ញុំទ័ពអត់សួរចាប់អារម្មណ៍ ។

ដានី៖ តែគាត់បងប្អូន តា ម៉ុក បង្កើតតែម្តង?

វើត៖ និត កាលជំនាន់ហ្នុងដឹងថាប្អូនបង្កើត តែឥឡូវនេះមិនដឹងជាយ៉ាងម៉េច ។

ដានី៖ ឥឡូវគាត់នៅស្រុកកំណើតគាត់?

វើត៖ មិនដឹងជាអាចទៅនៅស្រុកកំណើត ឬគាត់ស្លាប់ វាមិនច្បាស់ដែរ ព្រោះវាបែកគ្នាពី៧៩ មកឥឡូវវាយូរ តាំងពី៧៧, ៧៦មកណា ព្រោះពីដើមគាត់ជាសមាជិកស្រុកអន្លុងវែង ហ្នឹង ជំនាន់ខ្ញុំនៅ ។

ដានី៖ បើតា សាន គាត់មិនមែននៅខាងអន្លុងវែងទេ?

វើត៖ តាសាន អត់ទេ ។

ដានី៖ ខ្ញុំធ្លាប់សម្ភាសន៍គេមួយដូចថាមានពីរនាក់ ដូចមាន តា សាន តា សៀង ហ្នឹង គាត់មាន ទំនាស់ឈ្មោះគ្នា ពីមុនមកមានឮទេ?

វើត៖ ខ្ញុំអត់ដឹងរឿងហ្នឹង ខាងមូលដ្ឋានខ្ញុំអត់ដឹងទេ បើថាកងទ័ពខ្ញុំអាចនិយាយបានខ្លះៗ អាចដឹង ខ្លះ ។

ដានី៖ ចុះប្អូនថ្លៃ តា ម៉ុក មួយទៀតនោះ?

វីតៈ	ប្អូនថ្លៃតាម៉ុកមួយទៀត មាន តា ចំ, តា ចំ ដូចជាស្លាប់បាត់ហើយ ។

ដានីៈ	តា ម៉ុក គាត់មានបងប្អូនបង្កើត តា ម៉ុក បងគេ ។ តាម៉ុក មានបងប្អូនប៉ុន្មាននាក់ពូចាំទេ?

វីតៈ	ខ្ញុំមិនបានដឹងដែរ ខ្ញុំដឹងតែអ៊ឹ និត ហ្នឹងថាប្អូនពៅ, អាហ្នឹងទាល់តែសួរ មីង គេន ប្តីអ៊ឹ ទិត នេះ អ៊ឹ ទិត ប្អូនថ្លៃគាត់ មីងគេន ហ្នឹងប្អូនតា បង្កើត អ៊ឹ និត បង មីង គេន, មីង គេន មីង គួប, មីង គឿន ហ្នឹង បងប្អូនតាច្រើនតើ ប្រុសតែពីរទេ ។ ឥឡូវប្អូនឯងកុំអាលសរសេរ ខ្ញុំចង់និយាយថា ខ្ញុំវាក្តាប់មិនបានទេណា តែដឹងថា អ៊ឹ និត ប្អូន តា កូនប្រុសវាអាចមានតែពីរហ្នឹង ខាងខ្សែមីងគេនហ្នឹង មានមីងគេន, មីងគួប, មីងគឿន មានបីស្រីៗនេះ ។

ដានីៈ	តា សាន ហ្នឹងត្រូវ?

វីតៈ	តា សាន ហ្នឹងប្អូនថ្លៃទេ ។

ដានីៈ	ប្រពន្ធគាត់ពីណាគេ?

វីតៈ	មិនដឹងថា ប្រពន្ធមីងគឿន ឬមីងគួប វាភ្លេចហើយ នៅក្នុងហ្នឹងឈ្មោះហ្នឹងវាស្រដៀងគ្នា ហើយមីង គេន នេះ អ៊ឹ ទិត នេះហើយ ឧត្តមសេនីយត្រី យឹម ទិត ហ្នឹង ឥឡូវគាត់ចូលនិវត្តន៍ហើយ ។

ដានីៈ	អ៊ឹ ទិត ហ្នឹងគាត់នៅស្រុកណា?

វីតៈ	អ៊ឹ ទិត គាត់សាស្ត្រាចារ្យខ្សែអ្នកស្រុកហ្នឹងជាមួយគ្នា ពីដើមគាត់សាស្ត្រាចារ្យ ។

ដានីៈ	តែកាលជំនាន់...?

វីតៈ	ជំនាន់ពីមុនគាត់អនុតំបន់១៣ហ្នឹងហើយ អ៊ឹ ទិត មួយទៀត និយាយរឿងសមាជិកតំបន់ អ៊ឹ ទិត គាត់ទៅគ្រប់គ្រងគិរីវង្ស ។

ដានីៈ	ចុះគិរីវង្សក្រែង តាគុំ?

វីតៈ	តា គុំ ហ្នឹង គាត់ជាលេខា ហើយអ៊ឹ ទិត ហ្នឹងគាត់ជាប់តំបន់ ដល់ក្រោយមកអ៊ឹ ទិត ឡើងតំបន់នេះ ពេលដកអ៊ឹ និត ចូលជាមួយអ៊ឹ និត អីនេះ ខ្ញុំទៅក្រចេះផុតហើយ ។

ដានីៈ	តែគាត់នៅគិរីវង្សដែរ?

វីតៈ	បាទ! គាត់នៅគិរីវង្ស ។

ដានីៈ	ពេលពូនៅគិរីវង្ស គាត់នៅគិរីវង្សដែលអត់?

វីតៈ	គាត់នៅតើ ។

ដានី:	គាត់នៅជាមួយ តា តែម ដែរ?

វើត:	តាតែម តា តុំហ្នឹងហើយ ។

ដានី:	តែគាត់ធំជាង តាតែម តុំ?

វើត:	អត់ទេ! គាត់ទាបជាង គាត់អនុតាតុំទេ ដល់ពេលគេចាប់តា តុំនេះ បានគាត់ឡើងតំបន់ ។

ដានី:	ដល់ពេលអីចឹងមកពេលគេចាប់ឈ្មោះ ផន យោធាតំបន់នេះ ដល់នេះបងលោកពូ គាត់យកលោកពូទៅ?

វើត:	បាទ!គាត់យកខ្ញុំពីហ្នឹងទៅខ្វាចជាប់ពាក់ព័ន្ធនោះ ហៅខ្ញុំទៅក្រចេះទៅ បានជាខ្ញុំទៅ ។

ដានី:	ចុះយ៉ាងម៉េចបានពូដឹងថ្ងៃរៀបចំកងពល១១៧ ពូអាចរៀបរាប់ប្រាប់ខ្ញុំបានទេ?

វើត:	ព្រោះរៀបចំ១១៧អីចេះចាំមើល យួនចូលកាលហ្នុងរៀបជាមជ្ឈិមហើយណា កងមជ្ឈិមព្រោះកងពលទី១ហ្នឹងត្រូវរៀបហ្នុងពូខ្ញុំក្នុងហ្នឹងពីដើមគាត់ជាវរសេនាធំដែរ ពូ ចិន ហ្នឹងនៅវរសេនាធំហ្នុងមួយ ឈុំ ចិន គាត់នៅវ១៥ មិនដឹង១៦ ឬ១៥ទេ ។

ដានី:	ឈ្មោះ អី ចិន?

វើត:	ពូខ្ញុំ ឈុំ ចិន ដល់អីចឹងពូខ្ញុំហ្នឹងនិងពូ រុំ ហ្នឹងគាត់រាប់អានគ្នាដូចជាបងធម៌ប្អូនធម៌អីចឹងណា គាត់នៅមន្ទីរជាមួយគ្នាជាមួយ តា មុត ហ្នឹងរហូត អាហ្នឹងចាប់គ្នាជាមួយពូ រុំ ហ្នុងហើយដែលខ្ញុំថាហ្នឹង ។ ដល់អីចឹងគាត់ដឹងពាក់ព័ន្ធខ្លាចចាប់អ្នកគិរីវង្សនោះ វាពាក់ព័ន្ធដល់ខ្ញុំគាត់ហៅខ្ញុំទៅហ្នុងទៅ ទៅហ្នុងគេចាប់នៅហ្នុងទៀត ចប់បណ្តោយ ។

ដានី:	ពូចេញពីគិរីវង្សទៅក្រចេះតែម្តង ឬយើងមកលង្វែក?

វើត:	អត់ទេ! ខ្ញុំចូលមកភ្នំពេញបណ្តោយ ។

ដានី:	ចូលដល់ភ្នំពេញកងពល១១៧មានហើយ?

វើត:	មានហើយ រៀបហើយ កប៉ាលដូនទៅ នៅកម្មាភិបាលទេ ដែលនៅជិះយន្តហោះ ។

ដានី:	ប៉ុន្តែលោកពូពេលដែលគេរៀបកងពលហ្នឹងជាកងពលមជ្ឈិមហ្នឹងរៀបនៅកំពង់ឆ្នាំង ឬរៀបនៅណា?

វើត:	រៀបនៅកំពង់ឆ្នាំងមិនដឹង រៀបនៅលង្វែកមិនដឹងទេ កងពលរៀបហើយ ។

ដានី:	រៀបហើយបានគេបញ្ជូនទៅភ្នំពេញ?

វើត:	បាទ!

ដានី:	ពេលដែលគេរៀបហ្នឹងពូមិនទាន់ចូលទេ?

វើត:	អត់ទេ ខ្ញុំមិនទាន់ចូលទេ ។

ដានី៖ តែពូដឹងថាគេរៀបដើមឆ្នាំ៧៧ហ្នឹង?

វើត៖ បាទ! ដើមឆ្នាំ៧៧ ព្រោះខ្ញុំទៅខែ៣ឆ្នាំ៧៧ ហ្នឹងគេរៀបហើយ ។

ដានី៖ ដល់គេរៀបហើយប្រធានកងពលឈ្មោះអី?

វើត៖ ឈ្មោះ រុំ ។

ដានី៖ រុំ ហ្នឹងគាត់?

វើត៖ រុំ ហ្នឹងគាត់វរសេនាធំនៅណា ខ្ញុំមិនសូវយល់ដែលណាស់ ។

ដានី៖ កាលពីមុនមកមានដែលស្គាល់គាត់ដែរទេ?

វើត៖ ស្គាល់កាលពីជំនាន់និរសាអីខ្ញុំស្គាល់ ។

ដានី៖ ដឹងថាស្រុកកំណើតគាត់នៅណា?

វើត៖ រុំ ស្រុកកំណើតគាត់នៅស្រែក្នុង តែមុនឆ្នាំ៧៣-៧៤គាត់នៅជាមួយ តា មុត នៅនិរសា នៅជាមួយគ្នា គ្រាន់តែមន្ទីរខុសគ្នាណាស់ ខ្ញុំនៅ១៦០ ពូ រុំ ហ្នុ ងគាត់ធ្លាប់នៅមន្ទីរ ២០៤ កន្លែងមន្ទីរអបរំ ។

ដានី៖ កាលពីចូលដំបូងឋានៈប្រហែលៗពូអីទេ?

វើត៖ កាលចូលទៅពូ រុំ គាត់មេក្រុម ខ្ញុំកូនពួកហ្នឹង តែដល់ឡើងទៅគាត់ធំជាង ព្រោះគាត់ខ្សែ ខ្សែខាងខ្ញុំនេះវាឃឹតបន្តិចចុះ ។

ដានី៖ ខ្សែគាត់ខ្សែខាង?

វើត៖ ខ្សែខាង តា មុត នោះ ។

ដានី៖ ហើយគាត់ត្រូវជាក្មួយរបស់ តា មុត បង្កើត?

វើត៖ បាទ! ក្មួយ មាស មុត ។

ដានី៖ ម្ដាយគាត់និង តា មុត បងប្អូនបង្កើត?

វើត៖ ក្មួយគាត់ និងតាមុតបងប្អូនបង្កើត ។

ដានី៖ ដល់ពេលគេរៀបកងពល១១៧ហ្នឹងទៅ គេជ្រើសរើសគាត់ឲ្យធ្វើជាប្រធាន?

វើត៖ បាទ!

ដានី៖ ចុះអនុគាត់?

វើត៖ អនុគាត់ពូ លាង អាហ្នឹងនិយាយអ្នកទៅក្រចេះទេណា ។

ដានី៖ ចុះ លាង ហ្នឹងពីមុនមកលោកពូមានស្គាល់គាត់ទេ?

វើត៖ ពីមុនមកគាត់ក៏ជាវរសេនាធំដែរ វរសេនាធំនៅជាមួយអ៊ឹ សឿន ដែរ អ៊ឹ សឿន គាត់ជាអ្នករៀបចំ ខ្មោច អ៊ឹ សឿន ព្រោះអ៊ឹ សឿន គាត់ប្រធានកងពល ។

ដានី៖ តា សឿន គាត់ជាកងពលទី១របស់ភូមិភាគបស្ចឹមហ្នឹង?

វើត៖ ហ្នឹងហើយ អ៊ឹ សឿន គាត់ជាអ្នករៀបចំទាំងអស់បង១ហ្នឹង ព្រោះសុទ្ធតែជំនិតអ៊ឹ សឿន ហើយដែលទៅនេះ ។

ដានី៖ អីចឹង រុំ ហ្នឹងក៏នៅជាមួយ តា សឿន ដែរ?

វើត៖ នៅជាមួយអ៊ឹ សឿន បំបែកឆ្នាំ៧៥ហ្នឹង គឺចេះឆ្នាំ៧៥ហ្នឹង បំបែកកងពលហើយណា ភូមិភាគនិរតីមានបីកងពលហ្នុង គឺទី១ហ្នឹងកាត់មកភូមិភាគបស្ចឹមហើយ ទី២និងទី៣នៅខាងណុះ តែនិរតីគ្រប់គ្រងមួយកងពលទេ ខាងជើងទឹក ខាងតា មុត នេះ គាត់កាត់មកអគ្គសេនាធិការ វាផ្សេងហើយណា ទី១កាត់មកផ្សេងមកបស្ចឹម ។

ដានី៖ ដល់ពេលបែកឆ្នាំ៧៥កងពលទី៣របស់ តា មុត គាត់ចូលទៅខាង?

វើត៖ ទៅខាងអគ្គសេនាធិការវិញហើយហ្នឹង មជ្ឈិមគ្រប់គ្រង កងមជ្ឈិមហើយ អត់មានពាក់ព័ន្ធជាមួយខាងភូមិភាគទេ អាហ្នឹង អ៊ឹ មុត តាបញ្ជាលែងបានហើយ ដល់ តា សឿន នេះ តា បញ្ជាលែងបានហើយ នៅលើ តា ស៊ី វិញ ។

ដានី៖ អីចឹង តា មុត គាត់ឡើងទៅជាអគ្គសេនាធិការគាត់គ្រប់គ្រងកងពលជើងទឹកវិញ?

វើត៖ ជើងទឹកផងហើយគាត់រួមជាមួយតា ខៀវ នេះ, ជាមួយតា សុន សេន រួមទូទាំងប្រទេស គាត់ជាអគ្គសេនាធិការរង ដល់អីចឹងគាត់គ្រប់គ្រងទិសទាំងអស់ ។

ដានី៖ តា មុត គាត់កាន់ទិសណា?

វើត៖ តា មុត កាលហ្នឹងគាត់នៅកំពង់សោមហ្នុងមែន តែគ្រាន់កិច្ចការជើងគោក គាត់មានសិទ្ធគាត់ជំនួស តា ខៀវ បាន កិច្ចការអីបញ្ជូនទាំងអស់ឡើងអី តា មុត គាត់មានសិទ្ធបញ្ជាបាន ។

ដានី៖ តា មុត គាត់កាន់សមរភូមិទីសនៅខាងណាទៅ កាលពេលវាយ?

វើត៖ គាត់កាន់ខាងកំពង់សោម... ឆ្នាំ៧៨នេះ បានគាត់ទៅក្រចេះបានតែបន្តិចហ្នឹង ទៅក្រោយចាប់អ៊ឹ វន វើត ហើយទេ ។

ដានី៖ គាត់ទៅទទួលទិសខាងក្រចេះវិញ?

វើត៖ បាទ! ហ្នឹងប្រកព្រំដែន ។

ដានី៖ ខ្ញុំបកមកលោកពូវិញ ពេលដែលលោកពូទៅដល់ មកដល់ភ្នំពេញនេះពូទៅជាមួយកងពល គេ កងពល១១៧ហ្នឹង?

វើត៖ បាទ! កងពល១១៧ហ្នឹងដដែល ជិះកប៉ាល់ទឹកមក មេគង្គ កប៉ាល់ទឹកធំ ។

ដានី៖ លោកពូមានតួនាទីអីពេលទៅ?

វើត៖ ខ្ញុំទៅដល់មិនទាន់រៀបចំទេ ដល់ទៅបានប្រហែលជាមួយខែ មួយខែជាងបានរៀបចំក្នុង គណៈមន្ទីរ ខ្ញុំមិនប្រធានទេ ខ្ញុំអនុប្រធានមន្ទីរ ឈ្មោះ ផល ជាប្រធាន ។

ដានី៖ ប្រធានមន្ទីរឈ្មោះ ផល,លោកពូឈ្មោះ វើត អនុប្រធាន?

វើត៖ បាទ ។

ដានី៖ អនុប្រធានមន្ទីរកងពល?

វើត៖ បាទ ។

ដានី៖ មន្ទីរកងពលបើយើងនិយាយពីឋានៈវិញវាស្មើវរសេនាធំ ឬវរសេនាតូច?

វើត៖ យើងមានសិទ្ធបញ្ជាបានត្រឹមវរសេនាធំយើងបញ្ជាបាន យើងមានសិទ្ធជំនួសមុខឲ្យកងពល បាន ។

ដានី៖ ត្រឹមប្រធានមន្ទីរកងពល ដូចជាឋានៈប្រធានវរសេនាធំអីអត់អាចថា ប្រធានវរសេនាធំ មកបញ្ជាយើងបានទេ?

វើត៖ អត់ទេ! ប្រធានមន្ទីរមានសិទ្ធជំនួសមុខឲ្យកងពលបាន ដូចជាសំភារៈចាត់ចែងអីនៅលើ ប្រធានមន្ទីរទាំងអស់ ។

ដានី៖ អីចឹងកងពល១១៧ដំបូង ទៅដល់ហ្នឹង តា រុំ គាត់ក្តាប់រួម តា លាង គាត់អនុទទួល ខាងប្រធានយោធា ហើយសមាជិក?

វើត៖ សមាជិក នីម ។

ដានី៖ សមាជិកហ្នឹងគាត់ទទួលខាងអីទៅ?

វើត៖ គាត់ទទួលខាងសមរភូមិ គាត់ចុះជាប់តែមុខ ។

ដានី៖ ដល់ពេលក្នុងកងពលហ្នឹងមានបីវរសេនាធំ?

វើត៖ មានបីមានវ១៥មាន១៦មាន១៧ ។

ដានី៖ ១៥ពីណាគេប្រធាន?

វើត៖ កាលហ្នឹង បង ផន ។

ដានី៖ ហើយអនុ ផន មានពីណាគេ?

វើតៈ ខ្ញុំវាមិនបានចាំដែរវាភ្លេចក្រដាសស្នាម ។

ដានីៈ ដល់ពេល១៦?

វើតៈ កាលហ្នឹងដូចជាមាន បង ខន ឬបង ឈុត មិនដឹង ។

ដានីៈ បង ឈុត១៧?

វើតៈ ហ្នឹង បង ឈុត១៧! មួយទៀតពីណាដូចជាបងខន ឬពីណា១៦ហ្នឹងវាអត់ចាំ ។

ដានីៈ ១៦ក្រែង នីម ហ្នឹងគាត់កាន់១៦ផង?

វើតៈ អត់ទេ! ក្នុងហ្នឹងគាត់គ្រាន់ជាគណៈអចិន្ត្រៃយ៍ តែគាត់សមាជិកកងពល គ្រាន់តែនៅក្នុងវរសេនាធំហ្នឹងទេ តែមានប្រធានគេដោយឡែកមួយទៀត ។

ដានីៈ កាលហ្នឹងមានវរសេនាតូច?

វើតៈ អន្តរាគមន៍ ។

ដានីៈ វរសេនាតូចឯករាជ្យអន្តរាគមន៍?

វើតៈ មានកងពិសេស ។

ដានីៈ កងពិសេសហ្នឹង ពីណាគេប្រធាន?

វើតៈ ខ្ញុំភ្លេចភ្លាំងអស់ហើយ! និយាយរួមទៅវាអត់ចាំដល់ឥឡូវហ្នឹងភ្លេចអស់ ដល់ឃើញសួរវ៉ាក់អើអីចឹងទៅ ដូចថាវាគ្រាន់តែឃើញស្គាល់ បើឲ្យចាំ វាអត់ចាំទេ ។

ដានីៈ ហើយវរសេនាតូច ១២២,១០០អីមានដែរអត់?

វើតៈ វរសេនាតូចមានគ្រប់លេខ ។

ដានីៈ មានលេខប៉ុន្មានខ្លះ?

វើតៈ លេខហ្នឹងខ្ញុំវាភ្លេចដែរ មានកងអន្តរាគមនមាន៍អីទាំងអស់ហ្នឹង រៀបទាំងអស់តែភ្លេចអស់ទៅណាស់ ខ្ញុំនិយាយថាវាភ្លេច និយាយតែមួយម៉ាត់អីចឹងទៅ ភ្លេចច្រើនអត់ចាំ ទាល់តែរំលឹកមកអីចឹងបានដឹង ។

ដានីៈ ខ្ញុំធ្លាប់ទៅអន្លង់វែងទៅជួបបានដឹងចំនួនដូចថា ដូចថាវរសេនាធំ «វ-១៥»ហ្នឹងមានឈ្មោះផន គាត់ប្រធាន, ហើយ«វ-១៦»ហ្នឹងឈ្មោះ នីម ប្រធានវរសេនាធំ ហើយមានតួនាទីជាសមាជិកកងពល?

វើតៈ បាទ!

ដានីៈ ហើយ«១៧»កាលពីមុនមកបំផុត លាង គាត់ធ្វើប្រធាន ហើយក្រោយមកឡើង ឈុតធ្វើប្រធាន ហើយទៅជា...។

វើត: ហ្នឹងហើយ ខ្ញុំវាចាំមិនអស់ ពេលហ្នឹងវាអត់បានគិតរឿងប្រធាន ឬអនុអីទេណា តួនាទីខ្ញុំ តែដឹកសម្ភារៈពីភ្នំពេញមកក្រចេះពីក្រចេះទៅភ្នំពេញ ដូចថាការដោះស្រាយម្ហូបអាហារអី កងទ័ពខ្ញុំមានសិទ្ធតែប៉ុណ្ណឹងទេ ។

ដានី: កាលហ្នឹងមន្ទីរកងពលទៅណាទៅ?

វើត: នៅក្រុករយើងខាងជើងក្រចេះហ្នឹង ។

ដានី: នៅក្នុងតំបន់ក្រចេះហ្នុងតែម្តង?

វើត: នៅខាងជើងបន្តិចខាងជើងប្រហែលដីមួយគីឡូ ។

ដានី: កាលហ្នុងមន្ទីរកងពលនិងអ្នកនៅខាងតំបន់យើងធ្វើការជាមួយគ្នា ឬក៏ដាច់ពីគ្នា?

វើត: ដាច់ដោយឡែក តំបន់គេដាច់ដោយឡែក ។

ដានី: កាលហ្នុងតំបន់ក្រចេះពីណាគេប្រធាន?

វើត: បង មឿន ។

ដានី: ៥០៥ មឿន អ្នកស្រុកណាដែរ?

វើត: មឿន អ្នកស្រែក្នុងដែរ ។

ដានី: ត្រូវជាជាប់បងប្អូនជាមួយ?

វើត: ខ្សែតាមុត! ប៉ុនពីមុនដែលគាត់ទៅក្រចេះហ្នឹង គាត់នៅខាងអគ្គរបុរី គាត់នៅខាងវរសេនាធំ១៨ កងទ័ព ដកពីកងទ័ពទាំងអស់ អ្នកទៅក្រចេះភាគច្រើន ។

ដានី: ដកពីទ័ពទៅ?

វើត: បើ បង ខុន អាហ្នឹងគាត់ ។

ដានី: ខុន ហ្នឹង គាត់អនុ?

វើត: បង ខុន អនុ ។

ដានី: ខុន ហ្នឹងគាត់ខ្សែខាងណាដែរ?

វើត: ប្រពន្ធគាត់បងវ៉ា អ្នកស្រុកស្រែរនោង ប្រពន្ធបង ខុន គណៈតំបន់ហ្នឹង អ្នកស្រុកស្រែរនោងប្រពន្ធរបស់គាត់ ។

ដានី: អ្នកស្រុកស្រែរនោងខាងខ្សែរបស់តា?

វើត: របស់តាដែរ! បងវ៉ាប្រពន្ធគាត់ ។

ដានី: ហើយគាត់ខ្សែជាមួយតាសារឿន០៥អីដែលអត់ទេ?

រើត៖ អាចៗជាប់ជាមួយ០៥ហ្នឹង ខ្ញុំមិនសូវយល់ដែរ ប៉ុន្តែអ្នកស្រែក្នុងភាគច្រើនគឺ០៥ ជាប់ជាមួយ០៥ ។

ដានី៖ ០៥ ហើគាម៉ុតត្រូវជាយ៉ាងម៉េចគ្នាដែរ?

រើត៖ អាចសាច់ឆ្ងាយអីចឹងក៏មិនដឹងព្រោះពូ០៥ទៅនៅហ្នឹង តាំងពីឆ្នាំ៧០ណុះ...!

ដានី៖ បាទ! លោកពូមានប្រសាសន៍មិញទាក់ទងថា ឪពុកមា ពូលោកពូយកលោកពូពីគិរីវង្ស ទៅកងពល១១៧ តែពូរៀបរាប់មិញដូចអត់មានឈ្មោះពូរបស់លោកពូ មួយណា?

រើត៖ ឈុំ ចិន នៅគណៈស្រុកស្នួល ។

ដានី៖ គាត់ធ្វើគណៈស្រុកស្នួល?

រើត៖ លេខាស្រុកស្នួល ហៅ ភ័ណ្ឌ ទៅដល់ហ្នឹងកែឈ្មោះភ័ណ្ឌវិញ ។ អាហ្នឹងវរសេនាធំ១៦ ចាស់ ជាមួយពូលាង ឬជាមួយពូនីមទេ វាខ្សែស្រឡាយ...។

ដានី៖ ស្នួល! គាត់ឈ្មោះ ឈុំ ចិន ហៅ ភ័ណ្ឌ ។

រើត៖ ចាប់ជាមួយពូ រុំ ពួកម៉ាកគាត់ គ្នាគាត់ហ្នឹង ។

ដានី៖ កាលហ្នឹង១០៥ហ្នឹងមានប៉ុន្មានក្រុមទៅ លោកពូចាំទេ តំបន់១០៥ហ្នឹងមានស្រុកប៉ុន្មានទៅ?

រើត៖ បាទ! មានតំបន់១០៥ឯណា? ៥០៥?

ដានី៖ ហ្នុ! ៥០៥ ។

រើត៖ ៥០៥ មានស្រុកស្នួល ស្រុកសម្បូរ ស្រុកក្រចេះ ព្រែកប្រសព្វ មានតែប៉ុណ្ណឹងស្រុកហ្នឹង ពីមុន ពីមុនមាន៤ស្រុកហ្នឹង ។

ដានី៖ ព្រែកប្រសព្វនៅខាងភូមិភាគកណ្តាល?

រើត៖ ដល់គាត់ទៅភូមិភាគកណ្តាលទៅមក ខាងកើតទន្លេ មាននៅតែសម្បូរ ស្នួល ក្រចេះ ហៅ តំបន់ស្វ័យយ័ត ។ កាលបីឆ្នាំដាក់តំបន់ស្វ័យយ័តតើក្រចេះ អត់មានចូលជាមួយភូមិភាគណាទេ ។

ដានី៖ ស្រុកក្រចេះ...!

រើត៖ បាទ! ស្រុកក្រចេះ ស្នួល ស្រុកសម្បូរ តែបីស្រុកហ្នឹងឯង...។

ដានី៖ អីចឹងឪពុកមារបស់លោកពូ ឈ្មោះ ឈុំ ចិន ហៅ ភ័ណ្ឌ ហ្នឹង គាត់លេខាស្រុកស្នួល ហើយស្រុកសម្បូរពីណាគេទៅ?

វើត៖ ស្រុកសម្បូរបងវឿននៅ រាល់ថ្ងៃនៅតើ បងវឿនឥឡូវកងពលនៅព្រះវិហារ បងវឿន គាត់អ្នកកំពង់ឆ្នាំង ។

ដានី៖ វឿន គាត់នៅឯណា?

វើត៖ ឥឡូវនៅអន្លង់វែង ប្រពន្ធគាត់ឈ្មោះភាព ។

ដានី៖ ប្រពន្ធឈ្មោះ ភាព?

វើត៖ បាទ! អ្នកកំពង់ឆ្នាំង ។ មាឌធំដូចតាម៉េតអីចឹង ខ្សែខាងតាម៉េត ស្លាប់មុននេះដែរ ។

ដានី៖ តាវឿនហ្នឹងគាត់ធ្វើប្រធានកងពលហ្នឹងអី?

វើត៖ បាទ! អាឡូវគាត់ប្រធានកងពល ។

ដានី៖ ឥឡូវកងពលគាត់មកខាងនៅឯព្រះវិហារ?

វើត៖ បាទ! ពីមុនគាត់ស្រុក ប៉ុននៅតែគាត់មួយទេស្រុក បងយ៉េងអីនៅស្រុកក្រចេះហ្នឹង មិនចាប់ ចាប់មកជាមួយបងរុំ ១១នាក់ទាំងអស់ សួរបង ឌុល បង ឌុល បានដឹង សួរ បង ឌុល បានដឹងរឿងខ្មៅចទាំងអស់ ខ្ញុំវាភ្លេចថ្ងៃចាប់ ។

ដានី៖ យ៉េងនេះក៏ចាប់ ។

វើត៖ យ៉េងនៅស្រុកក្រចេះ! អត់តែបងវឿនទេ ។ បងវឿនគាត់អត់មានពាក់រឿងថ្ងៃប្រជុំ អ៊ឹ វ៉ន វើត ទៅប្រជុំ បង ឌុល គាត់គណៈមន្ទីរ ដល់ចឹងថ្ងៃអ៊ឹ វ៉ន វើត ទៅប្រជុំ ដូចខ្ញុំអី ទៅទទួលហ្នឹង អ៊ឹ វ៉ន វើត ទៅដល់ភ្នំពេញ បានចាប់អ្នក១១នាក់នេះ ។

ដានី៖ អីចឹងរួចតែតាវឿនមួយ ។

វើត៖ បងវឿនគាត់អត់មានបានចូលប្រជុំអា១១នាក់នេះ ដែលចាប់មកចូលទួលស្លែងនេះ ។

ដានី៖ ពូអាចរៀបរាប់អាពេលហេតុការណ៍ គេចាប់ដូចថា កាលហ្នឹងទាំងគណៈតំបន់ ទាំងគណៈ កងពល គណៈតំបន់៥០៥ ទាំងគណៈកងពល១១៧ គេហាក់ដូចជាគេហៅមកប្រជុំទាំង អស់គ្នាហើយបានគេចាប់ ឬយ៉ាងម៉េច?

វើត៖ ចង់និយាយអីចេះ បើតាមខ្ញុំយល់ខ្លួនខ្ញុំ ឬក៏ខ្ញុំក្តាប់បានទេណា ព្រោះក្នុងខ្ញុំមន្ទីរផង ខ្ញុំនិរសា ផងណា សម្រាប់ការពារភ្ញៀវ ឬការពារអ្នកដឹកនាំអីចឹងណា ។ គេហៅខ្ញុំមកប្រជុំកន្លែង កងពល ខ្ញុំមិនត្រូវរៀបចំមន្ទីរខ្ញុំ ដល់ប្រជុំតំបន់មិនមន្ទីរតំបន់គេរៀបចំ ដល់អ៊ឹ វ៉ន វើត គាត់ឡើងមកក៏គាត់មិនមែនសំដៅទៅលើកន្លែងតំបន់ទេ គាត់មកកងពល តែកងពលកន្លែង វាចង្អៀតណា ។ កន្លែងកងពលវាឃ្លាំងផងអីផងវាអត់សាលាប្រជុំដូចតំបន់វាមកប្រជុំនៅ សាលាផ្ទះតាមឿន តំបន់នេះ នៅក្រូង ។ ដល់ វ៉ន វើត មកប្រជុំដូចថាគាត់មកទស្សនៈ

កិច្ចផងមក ប្រជុំផង ទៅជួរមុខទៅព្រែកទេរ យួនមិននៅត្រើយកើត យើងមិននៅត្រើយលិចដល់អីចឹង គាត់ទៅដូចថារបៀបថតកាម៉េរ៉ាអីខ្លះ ប៉ុន្តមិនមែនដូចម៉េរ៉ាឥឡូវទេ អាសខ្មៅនោះណា ថតរូបទុកជាអនុស្សាវរីយ៍ គាត់ថតគល់ស្ពានអូរកន្ធួត ស្ពានឈើទេ ប៉ុនឥឡូវស្ពានថ្មហើយ ដល់ចឹងទៅ ទៅក្នុងរយៈកំឡុងដែលគាត់សម្រាកនៅត្រង់ហ្នុង គឺអត់បានវាយគ្នាទេ អត់វាយគ្នាទាំងអស់ គាត់ត្រឡប់មកសម្រាក់នៅក្រចេះវិញ ពេលហ្នឹងគាត់ជិះកប៉ាល់មកភ្នំពេញវិញ មកដល់ភ្នំពេញប្រហែលជា១ថ្ងៃ ឬ២ថ្ងៃមកដល់ ឮដំណឹងថាចាប់បណ្តោយហ្នឹង ។

ដានី: គេចាប់ពីណា?

វើត: ចាប់ វន វើត ណា ។ ពេលហ្នុងចាប់ វន វើត បានជាឃើញសំបុត្រនេះ ចាប់ហើយសំបុត្រដាក់ម-៨៧០ ដែលខ្ញុំឃើញ ធម្មតាខ្ញុំនៅក្នុងមន្ទីរហ្នឹងខ្ញុំត្រូវពិនិត្យសំបុត្រដែលបញ្ជូនពីលើទៅ មិនមែនអ៊ឹ មុត យកទៅផ្ទាល់ គឺនិរសាអ៊ឹ មុត ។

ដានី: និរសាអ៊ឹ មុត ហ្នឹងយកសំបុត្រទៅឲ្យ?

វើត: យកសំបុត្រទៅឲ្យ! ដូច្នេះបានន័យថាអ៊ឹ មុត យកទៅឲ្យទៅ តែតាមពិតអត់ទេ និរសាអ៊ឹ មុត អ្នកទូរលេខគាត់ហ្នឹងណា ឃើញដាក់ថា ម-៨៧០ ព្រោះ៨៧០បានន័យថាប្រធានមន្ទីររបស់រដ្ឋ របស់ ប៉ុល ពត ហើយ ដូន រុំ! ដល់ចឹងឃើញដាក់ ដូនរុំ អីចឹង ដូនអ្នកទាំងអស់ ដែលមានឈ្មោះនេះ១១នាក់នេះ មានឈ្មោះហ្នឹងឡើងមកប្រជុំភ្នំពេញ បានមករៀន ដល់មករៀនមិនត្រូវឡើងយន្តហោះជិះណាកាតា ដល់ចឹងខ្ញុំក៏បានចឹង មិនត្រូវជូនគាត់ ដូចថាណាត់គ្នា ដូចគណៈស្រុកស្នួល ពូខ្ញុំអីចឹងគាត់នៅឯវត្តថ្មក្រែលយើងហ្នឹង ឯភ្នំសំបុកហ្នឹងណា ហ្នឹងហើយមកទាំងអស់គ្នា នាំគ្នាមកនិយាយគ្នាក្នុងឡាន យើងទៅបានមកវិញ ឬមិនបានអីចឹងទៅណា ។

ដានី: គាត់ភ័យដែរចឹងកាលហ្នឹង?

វើត: ភ័យ! ដល់អីចឹងទៅពូ រុំ គាត់ថាន៉ែ! គាត់និយាយគ្នាគាត់ជាមួយប្រពន្ធគាត់ហ្នឹងណា ម៉េងហ្វែង បើអញស្លាប់ទៅកុំយកប្តីអី គាត់និយាយគ្នាគាត់លេង អាមុនហូបបាយរៀបចេញទៅហ្នឹងណា ម៉ោង៩បានយន្តហោះគេមកដល់បានទៅ ។ ដល់ចឹងទៅនាំគ្នាជិះឡានបង១ទៅបានខ្ញុំជូនទៅ ហើយអាកន្លែងព្រលានយន្តហោះហ្នឹង ក៏យើងធ្លាប់តែអាកន្លែងហ្នឹងយើងធ្លាប់តែចេញចូល បញ្ជូនសារទូរលេខអីយើងចេញចូលបាន ពេលថ្ងៃហ្នឹងអត់ឲ្យយើងចេញចូលទេ មិនឲ្យពួកខ្ញុំបើកឡានចូលទេ បិទ ។ បិទយើងមិនដើរទៅបង១កម្មាភិបាល

មិនដើរម្នាង គេអ្នកចុះទៅទទួល ខាងបងញ៉ាន់ មិនម្នាង ដល់ចឹងឡើងទៅ គេអ្នកចុះមក គេនៅឯហ្នឹងទៅ យន្តហោះឡើងទៅ ដល់ពួកខ្ញុំនេះបានមេរៀនហើយមិនទាំគ្នាសប្បាយ ទៅលេងស៊ីងត្រែងទៅលេងអីនេះ ។

ដានី: អូ! បាត់មេហើយ យើងសប្បាយ អត់មាននរណាគេគ្រប់គ្រង ។

វើត: កាពិតបង១តាមវរ តាមអីមិនដឹង ណាដឹង អត់ដឹងទេ ។ មកស៊ីងត្រែងមួយយប់ចឹង ខ្ញុំទៅវិញក៏បានសាច់ជនជាតិគេមានអាខាងបងសារឿន (០៥) គេមានសាច់ឆ្កៀតសាច់អីយកមកឲ្យទ័ពហូបហ្នឹងណា ។ ដល់ចឹងទៅ អត់ដឹងថាចាប់ទេ មកដល់កន្លែងបាន អ៊ឹ មុត ហៅប្រជុំ ហៅប្រជុំពួកមន្ទីរខ្ញុំនៅឃ្លាំងហ្នឹង គាត់ថាអាពួកមេហ្វែងក្បត់ហើយ ឥឡូវអាធំៗហ្វែងទៅវាយយួន អាតូចៗដឹកសម្ភារៈទៅស៊ីងត្រែង ។

ដានី: ហ៊ូ! ចឹងតាមុតគាត់មកប្រជុំប្រាប់ចឹងតែម្ដង ។

វើត: បាទ! ប្រជុំប្រកាសប្រាប់មេក្បត់ហើយនោះ ដល់ចឹងទៅបានពួកខ្ញុំទៅវាយយួនបាន៧០នាក់ កំលាំងពួកខ្ញុំនេះ បាទ! ៧០នាក់ហ្នឹងឲ្យទៅវាយនៅឯកន្ទួតហ្នឹង ចំអាមុខអាក្រោះហ្នឹង ប៉ុនអាក្រោះហ្នឹងពុំមានបានឆ្លងទេ ឆ្លងយប់ចឹងខ្ញុំរត់វាងពីជើង ត្បូងក្របេះហ្នឹង រត់ធ្លាក់ទឹកទន្លេ ។

ដានី: ចុះលោកពូមានប្រសាសន៍ថាពេលដែលទៅព្រលាន វាលយន្តហោះហ្នឹង ដែលកងទ័ពគេយាមគេអត់ឲ្យយើងចូល ដូចរាល់ដងយើងជិះបើកចូលបាន ។

វើត: អាហ្នឹងខាង៥០២ ខាងកងទ័ពជើងអាកាស គេនៅហ្នឹងមួយក្រុមដែរ គេនៅសម្រាប់បើកទ្វាបារ៉ាស់ហ្នឹងណា ។

ដានី: ចឹងមានកងពល៥០២ ទៅដល់ហ្នុងដែរ?

វើត: គេនៅតាមព្រលានៗ ៥០២នៅទាំងអស់ ។

ដានី: តាមព្រលានយន្តហោះ តាមគ្រប់ភូមិភាគគ្រប់តំបន់សុទ្ធតែ៥០២ នៅចាំនៅព្រលានទាំងអស់?

វើត: តាមព្រលានមួយៗ ហ្នឹងហើយមានទាំងអស់ ។ រតនគិរីក៏មាន តែគេនៅតិចទេ កំលាំងគេគ្រាន់តែ២-៣នាក់ៗហ្នឹងណា ។

ដានី: លោកពូមានប្រសាសន៍មុិញថាតាញ៉ាន់ គាត់ទៅតាំងពីអន្លុល?

វើត: គាត់ទៅនឹងចាប់ហ្នឹង ពេលឡើងយន្តហោះមកហ្នឹង ហ្នុងចុះ នេះឡើង ។

ដានី: អីចឹងពេលយន្តហោះមកហ្នឹង តាញ៉ាន់ គាត់ជិះទៅដល់ គាត់ចុះមក!

វើតៈ	គាត់ចុះមក អ្នកពីនេះឡើងទៅ ។

ដានីៈ	យន្តហោះមកអីគេ?

វើតៈ	ដាកាតា ហ្នឹងយន្តហោះដឹករបួស ។

ដានីៈ	ណាកាតា?

វើតៈ	ដាកាតា ដឹងតែជំនាន់ហ្នឹងហៅដាកាតា តែឥឡូវហៅលេខអី ។

ដានីៈ	យន្តហោះកន្ទុំរុយវិល?

វើតៈ	មិនមែនទេ ដាកាតាចុះរត់ដូចស្លាបកាត់អីចឹងណា ។

ដានីៈ	ជិះបានប៉ុន្មាននាក់យន្តហោះហ្នឹង?

វើតៈ	យន្តហោះដឹករបួសដេក២-៣នាក់នៅក្នុងហ្នឹងបាន របួសធ្ងន់ៗដាក់ទទឹង អត់មានកៅអីទេ កៅអីនៅខាង២-៣ៗទេ តែយើងដាក់របួសដាក់អី ប្រង់ការ ។

ដានីៈ	ប៉ុន្តែ១១នាក់ដែលទៅហ្នឹង ជិះទាំងអស់គ្នា១១នាក់?

វើតៈ	ជិះទាំងអស់ ។

ដានីៈ	១១នាក់ហ្នឹងលោកពូចាំឈ្មោះពីណាខ្លះ? ចាំមើលតា?

វើតៈ	ខ្ញុំស្គាល់តំបន់ ស្គាល់តែ២ហ្នឹង ។

ដានីៈ	ស្គាល់តាមឿន?

វើតៈ	តាមឿន ហើយនិងខុន ហ្នឹង ។

ដានីៈ	ហើយខាងកងទ័ព?

វើតៈ	កងទ័ពបងផន ហើយនិងរុំ ទេ ។

ដានីៈ	តែផន ហើយនិងរុំទេ, លាង អត់ទៅជាមួយទេ?

វើតៈ	កាលហ្នឹងវាមិនដឹងជាមួយអត់ទេ តែឈ្មោះក្នុងហ្នឹងវាមាន១១នាក់ហ្នឹង ក្នុងសំបុត្រ មិនដឹងបងលាង ទៅមុន ដូចថាទៅមុន ទៅមិនដឹងអីជិះអីទៅ ដែលបងលាងទៅ ខ្ញុំកំពុងតែឆ្ងល់ ព្រោះបើថាអត់ជិះទៅជាមួយគ្នា ទាល់តែសួរ បងខុល ។

ដានីៈ	អីចឹងចាំមើល ក្នុងចំណោមហ្នឹងដែលលោកពូចាំថា១១នាក់ហ្នឹង មានឈ្មោះមឿន ។

វើតៈ	វរសេនាធំខ្ញុំដឹង៤ ។

ដានីៈ	មានឈ្មោះមឿន ។

វើតៈ	អត់ទេ វរសេនាធំ ។

ដានីៈ	វរសេនាធំពីណាខ្លះ?

វើត៖ ខ្ញុំដឹងតែទៅក្នុងចំណោម១១នាក់ហ្នឹងមាន៤ វរសេនាធំមាន៤ កងពលមាន២ ។

ដានី៖ កងពល២ វរសេនាធំ៤?

វើត៖ បាទ ។ ៤បូក២ = ៦ ។ ៦បូកនឹងស្រុក២ = ៨ គណៈតំបន់ អាចមានគណៈតំបន់ទៅទៀត ។

ដានី៖ ចាំមើលកងពលមានវរសេនាធំ៤នាក់ ហើយគណៈកងពល២នាក់ ។

វើត៖ ៦ ស្រុក២ ស្មើរ៨ ។

ដានី៖ ហើយនឹងតំបន់ ។

វើត៖ តំបន់ខ្ញុំដឹង២ = ១០ ហើយបងឌុលទៅមួយ = ១១ ។

ដានី៖ ឌុល មួយទៀត១១ ។

វើត៖ ១១នាក់ ។

ដានី៖ ចុះវរសេនាធំ៤ហ្នឹងឈ្មោះអីទៅ? ពីណាខ្លះ?

វើត៖ ខ្ញុំដឹងតែបងផន មួយ ដល់រត់រញ៉េរញ៉ៃ មិនបាននៅទៀតណ៎ា ។

ដានី៖ ក្នុង៤នាក់ វរសេនាធំ៤នាក់ហ្នឹង ស្គាល់តែផន មួយទេ ៣នាក់ទៀតអត់ស្គាល់ទេ?

វើត៖ អត់ទេ និយាយរួមអត់បានចាប់អារម្មណ៍ មិនបានគិត ។

ដានី៖ គណៈកងពល២ ឈ្មោះរុំ ។

វើត៖ បើខ្ញុំទៅជាប់ជាមួយពូរុំ ប៉ុន្មាននាក់នោះខ្ញុំអត់បានគិត ។

ដានី៖ រុំ ហើយពីណាទៀត គណៈកងពលមាន២នាក់អីចឹង?

វើត៖ ជាមួយបងលាង តែថ្ងៃហ្នឹងមិនដឹងបងលាង ទៅជាមួយគ្នា ឬទៅមុនអីអត់ដឹង លឺថ្ងៃ២ខុសគ្នា ខ្ញុំឆ្ងល់ ព្រោះទៅមានតែមួយសារហ្នឹងឯង ។

ដានី៖ ទៅ ផន, រុំ, លាង ហើយគណៈស្រុក២ ពីណាគេ?

វើត៖ យ៉េង នៅក្រចេះ, ចិន ហៅ ភ័ណ្ឌ នៅស្នួល ។

ដានី៖ បើចិនហៅ ភ័ណ្ឌ ត្រូវជាឪពុកមាបង្កើតតែម្តង? ពូបង្កើត?

វើត៖ បាទ ប្អូនប៉ាខ្ញុំ ។

ដានី៖ ចិន ហៅ ភ័ណ្ឌ ។ ដល់ពេលគណៈតំបន់ពីរ ។

វើត៖ មឿន ហៅ កេត ហើយនិង ខុន ។

ដានី៖ ដល់ពេលឌុល គាត់ធ្វើអី?

វើត៖ គាត់ធ្វើប្រធានមន្ទីរតំបន់ហ្នឹង ។

ដានី៖ ឪល មួយប្រធានមន្ទីរតំបន់ ដល់ពេលយន្តហោះដែលជិះចុះមកហ្នឹងឃើញ ។

វើត៖ មាត់ជណ្ដើរចុះម្នាក់ម្នាក់ ។

ដានី៖ ចុះមានតាញ៉ាន់?

វើត៖ តាញ៉ាន់, តាផុន ហៅទី តាផុននៅស្ពាន, ជាមួយ តាប៉ក់ហ្នឹង ។ តាផុន ចេញពីឈូក គណៈស្រុកទៅ ។

ដានី៖ ឈ្មោះផុន?

វើត៖ ផុន ហៅទី ។

ដានី៖ ផុន ហៅទី ដែលថាប្រធានស្រុកជាមួយយាយ អ៊ំស្រី ។

វើត៖ អត់ទេហ្នឹងឈូក គាត់ទៅនៅស្ពានដែរ ទៅនៅជាមួយប៉ក់ ហ្នឹងដែរ ។ ប៉ុនមកហ្នឹងមាន ៣នាក់ហ្នឹងទេ សាន មួយទៀត ហ្នឹងនៅឈូកដែរ គាត់ខាងទ័ពស្រុកនៅស្ពាន គាត់ទ័ព ស្រុកទេ ។

ដានី៖ តាញ៉ាន់, ផុន ហៅទី ហី សាន ។

វើត៖ អត់ទេ ប៉ក់ ជីដូនមួយ... ។

ដានី៖ ផុន ហៅទី, ប៉ក់ ហ្នឹងមកដែរ?

វើត៖ ប៉ក់ មកជាមួយគ្នា តំណាលគ្នាហ្នឹងជាមួយ សាន ហ្នឹង ៤នាក់ហ្នឹង ។

ដានី៖ ចាំមើលមានញ៉ាន់, ផុន ហៅទី, មាន សាន ហើយ ប៉ក់ មួយទៀត?

វើត៖ បាទ ។

ដានី៖ គាត់មក៤នាក់ហ្នឹងគាត់មកទទួលខាងអីទៅ?

វើត៖ ញ៉ាន់ ប្រធានកងពល ។

ដានី៖ តាញ៉ាន់ ដឹបូងគាត់នៅណា?

វើត៖ គាត់នៅកំពង់សោម ។

ដានី៖ កំពង់សោមកងពលតាមុត?

វើត៖ បាទ ។

ដានី៖ កងពលតាមុត នៅកំពង់សោម ១៦៤ ។ កាលហ្នឹងគាត់តួនាទីអីនៅជាមួយតាមុត កាល នៅកំពង់សោម?

វើត៖ តួនាទីអាចនៅជាមួយបងសេង អាចកងពលជាមួយគ្នា ។

ដានី៖ អាចគណៈកងពល?

វ៉ីត: គណៈកងពលជាមួយគ្នា ។

ដានី: គណៈកងពលមកទទួលនេះ មកជាប្រធាន១១៧ ហើយចុះផុន ហៅទី កាលមុន គាត់?

វ៉ីត: អ៊ូ! បងភាព មួយទៀត ភាពស្លាប់បាត់ហើយ ភាព៨៨នៅជាមួយអ៊ឹមុត ដែរហ្នឹងនៅកំពង់សោម ។

ដានី: ភាព កំពង់សោម ។

វ៉ីត: តំបន់មានពីរមកដូរពីរហ្នឹង ។ បងភាព បងប្អូនបងភា យើងកងពល... ។

ដានី: អីចឹងមកតំបន់១០៥មាន ភាព ។

វ៉ីត: ៥០៥ ។

ដានី: ៥០៥ មានភាព ហើយផុន ។ ពីណាប្រធាន ពីណាអនុ?

វ៉ីត: កាលហ្នឹងបែបផុន ប្រធានហើយ ។ តែវត់មកគ្រាន់តែចូលមកមិនទាន់បាន២ថ្ងៃផងវត់ បើបងភាព គាត់ក្មេង ហើយបងភាព គាត់កាន់ទ័ពផង ។

ដានី: ផុន ប្រធាន ហើយភាព អនុ ។ ហើយភាព នេះគាត់មកកន្លែងតាមុត ១៦៤ ។ ហើយចុះតាសាន?

វ៉ីត: តាសាន នៅជាមួយប៉ក់ ។ ជាមួយទ័ពស្រុកស្អាង ប្រធានទ័ពស្រុក ហៅប្រធានទ័ពស្រុក ។

ដានី: មកពីស្រុកស្អាង ។

វ៉ីត: មិនមែន សាន យាយ វីន កងពលនេះទេ សាន ផ្សេង ។

ដានី: មិនមែន សាន (០៦) ទេ ។

វ៉ីត: បាទ មិនមែនសាន (០៦) ទេ ។

ដានី: សាន ហើយប៉ក់ មកពីស្អាង?

វ៉ីត: អ្នកស្រុកស្អាង ហើយផុន ក៏ស្រុកស្អាងដែរ អ្នកស្រុកស្អាងដែរ ជាមួយតាប្រាក់ ជាមួយតាជ័យ ចាប់អស់ដែរ ។

ដានី: អីចឹងសាន ហើយប៉ក់ គាត់មកធ្វើអី? មកទទួលអី?

វ៉ីត: មកនៅស្រុកក្រចេះ ជំនួសបងយ៉េង ។

ដានី: សាន ហើយប៉ក់ មកស្រុកក្រចេះ ។

វ៉ីត: ប៉ក់ ហ្នឹងលេខាស្រុក ហើយសាន ខាងយោធាស្រុក អត់តែស្រុកស្នួលទេអត់មានអ្នកជំនួស ។

ដានី៖ សាន យោធា! ស្រុកស្លួលម៉េចបានអត់មានអ្នកជំនួស គេយកបានហើយ?

វើត៖ គេយកបានហើយ មានអ្នកណាមកជំនួស បើទាំងមូលហើយ ពីម៉ោង៦ព្រឹកដល់ម៉ោង ៨យប់ យកបានស្លួលទាំងមូលហើយ ។

ដានី៖ ដល់ពេលខាងកងពលយកទៅអស់ពីរ យកមកវិញតែមួយហ្នឹង?

វើត៖ តែមួយ ។ មួយឡើងក្រោយឡើងបង ឈុត ។ នឹម នៅដដែល នឹម ដាច់ខាត គាត់អត់ រត់មកត្រើយលិចទេ នឹម សុខចិត្ត...។ ហើយយាយណាន់ ពេទ្យហ្នឹងបែបទៅនៅស្រុក កំណើតវិញ ខ្ញុំមិនដឹងទេ ។

ដានី៖ ពីណា?

វើត៖ ប្រពន្ធតានឹម ។ យាយណាន់ អ្នកត្រពាំងធំ ។

ដានី៖ យាយណាន់ ប្រពន្ធតានឹម ។

វើត៖ បាទ ។

ដានី៖ ប្រពន្ធឈ្មោះណាន់ ។

វើត៖ យាយណាន់ ។

ដានី៖ តានឹម គាត់នៅរស់តាំអី?

វើត៖ មិនដឹងជាម៉េច បើនៅអន្លង់វែង ដឹងគាត់រស់ដឹងស្លាប់ ប៉ុនខ្លាចតាវៃចោល បើតាមិនវៃ ចោលរស់ហើយ ។

ដានី៖ បើយាយណាន់ សព្វថ្ងៃគាត់រត់ទៅស្រុកកំណើតវិញហើយ?

វើត៖ វាមិនដឹងរត់ទៅណា ។

ដានី៖ អត់អីទេ ។ បន្ទាប់ពីគេហៅទៅបាត់ហើយ កងពល១១៧ហ្នឹងដាក់គាញ៉ាន់ ប្រធាន ហើយ អនុប្រធានពីណាគេ?

វើត៖ មានឈុត, មានតានឹម , ឈុតឡើង គ្រាន់តែរៀបហើយយួនចូលបណ្ដោយ ។

ដានី៖ អត់បានវៃ អត់បានអី?

វើត៖ អត់បានវៃទេ យួនបុកមួយសារទៀតហ្នឹង ថ្ងៃម៉្ដងជាង ។

ដានី៖ លោកពូនៅមន្ទីរ?

វើត៖ នៅមន្ទីរហ្នឹងក៏ខ្ញុំដឹកសម្ភារៈចេញ អត់មានបានអី កប៉ាល់ដឹកកាំភ្លើងត្រូវបើកកាំភ្លើងត្រូវ ដឹកឲ្យអ្នកនៅព្រៃកប្រសព្វ កំលាំងអត់ត្រូវនេះដឹកសម្ភារៈចេញមកស្ទឹងត្រែង ហើយអីចឹង វាបែកខ្ញែកគ្នាអស់ បែកបាក់ទ័ពអស់ហើយ ។

ដានី៖ អីចឹងកាលហ្នឹងគ្រាន់តែរៀបចំមិនទាន់បានអីផងក៏បែក?

វិត៖ អត់ទាន់ទេ អត់បានធ្វើអីកើតទាំងអស់ ។ កងពលតាញ៉ាន់ ក៏មិនស្គាល់មុខ ទាល់តែរត់មកដឹងថាកងពល ៗ ក៏រត់តាមគ្នាមក ។

ដានី៖ ប៉ុន្តែដូចវរសេនាធំបានរៀបជាប្រធានវរសេនាធំ ។

វិត៖ រៀបហើយ គ្រាន់តែរៀប ចាប់រៀប ៗ ទៅប្រជុំរៀបនៅខាងលិចព្រែកទេរហ្នឹង ក៏គ្រាប់ផ្លោងជាន់មកទៀត គ្រាប់ផ្លោងជាន់មិនទាន់បានប្រជុំទ័ពណា កំពុងតែហូបបាយ គ្រាប់ផ្លោងជាន់នៅកន្លែងហ្នឹង ចាប់មេវរៈធំតំបន់ ចាប់បងអឿង ហ្នឹងថាបងអឿង, យាយភ៉ម, បងអឿង វរសេនាធំតំបន់ក្រចេះហ្នឹងទៅពីស្រុកខាងតាកែវ ដល់អីចឹងបងញ៉ាន់ ថាបងអឿង កែតេអូម៉េចឲ្យគ្រាប់ផ្លោងជាន់ទ័ពក៏ចាប់វៃចោលត្រង់ហ្នឹងបាត់ទៀតទៅ បែកខ្ញែកគ្នា... ។

ដានី៖ អឿងហ្នឹងប្រពន្ធគាត់ឈ្មោះអី?

វិត៖ ភ៉ម ។

ដានី៖ អឿង ហ្នឹងអ្នកស្រុកនៅណា?

វិត៖ អឿង, ភ៉ម និងបងភ៉ា សាច់ឈាមគាត់អ្នកស្រែរនោង ។

ដានី៖ ស្រែរនោងដែរ?

វិត៖ បាទ ។

ដានី៖ តា ញ៉ាន់ ហ្នឹង! គាត់ឃើញគ្រាប់ផ្លោងធ្លាក់លើ គាត់ចោទថា អឿង ហ្នឹងអ្នក?

វិត៖ បាទ! ព្រោះគេអូអីរ៉ោករ៉ាក ៗ ហ្នឹង វាមិនដឹងរឿងអីក៏គាត់ខឹងក៏ស្លាប់ អាខ្លះកំពុងជ្រក់ស្ពៃនៅនឹងមាត់ ។

ដានី៖ ហើយចុះមុន អឿង ហ្នឹង! ពីណាគេនៅប្រធានវរសេនាធំ?

វិត៖ អឿង ណ្ហឹង! បងអឿង ហ្នឹងវរសេនាធំតំបន់តាំងពី ។

ដានី៖ តាំងពីជំនាន់ មឿន?

វិត៖ អត់ទេ! ជំនាន់មឿន ហ្នឹងហើយ ។ មឿន ទៅ មឿនចាត់តាំង ។

ដានី៖ តែពេលគេហៅ១១នាក់ហ្នឹង អត់មានឈ្មោះ អឿង ទៅទេ?

វិត៖ អត់មានទេ ។ គាត់អ្នកល្អ អ្នកត្រង់ ដល់ពេលគាត់ទទួលគ្រាប់ផ្លោងជាន់ទ័ពអញ្ចឹងទៅ ។

ដានី៖ ដូចថាខឹង?

វិត៖ ទ័ពខឹង ។

ដានី៖ ដូចថា តាញ៉ាន់ គាត់ខឹងបុគ្គលខ្លួនឯងផង។ ដល់ពេលឃើញទ័ពអញ្ចឹង?

វើត៖ បាទ! ចុះស្លាប់មិនមែននេះ ប្អូនហើយគ្រាប់ផ្លោងលេងព្រឹងមក មិនដឹងស្លាប់អីអត់លឺសូម្បី តែបាន ខ្ញុំទៅដឹកអ្នករបួសបានខ្ញុំដឹង។

ដានី៖ ចុះមុនហ្នឹងលោកពូមានប្រសាសន៍ថា វ៉ន វើត កាលហ្នឹងគាត់ទទួលខាងសមរភូមិ?

វើត៖ អឺវន វើត ចាំមើលខ្ញុំនិយាយ។ យួនបុកពីគ្រប់ទិស ស្ទួលហ្នឹងមិនទាន់យកបានទេ ស្ទួលហ្នឹងទើបតែនៅរោងចក្រអាឈើនៅឡើយ ពួករោងចក្រភ្នំពេញ អាហ្នឹងស្តាប់តាមវិទ្យុទេ ដល់អញ្ចឹងប្តេជ្ញាចិត្តទាំងអស់ត្រូវឲ្យអ៊ី វ៉ន វើត មកកាន់កងទ័ពជើងគោក ហ្នឹងក្នុងវិទ្យុ ឲ្យគាត់អ្នកគ្រប់គ្រងទ័ព ដល់អញ្ចឹងទៅត្រូវគាត់ហ្នឹងមកត្រួតពិនិត្យតាមប្រកយើង។ គាត់នៅក្រសួងខសួរ្យាហកម្មទេពីមុន គាត់នៅខាងក្រសួងខសួរ្យាហកម្មជាមួយពូ ជឿន ពូខ្ញុំ ដែលថាជីដូនមួយដែលចាប់ទៅហ្នឹង ជាមួយអ៊ី វ៉ន វើត ហ្នឹង។

ដានី៖ ជឿន ដែលគាត់ធ្វើគណៈស្រុកតាំងអង្គរជ័យហ្នឹងមក ក្រោយមកផ្លាស់មកនៅជាមួយ វ៉ន វើត។

វើត៖ បាទ! ហ្នឹងហើយ។ ដល់អញ្ចឹងចាប់ វ៉ន វើត ចាប់ពូខ្ញុំហ្នឹងដែរ បានដោយទៅពូខ្ញុំ ពូរុំហ្នឹងទៀត វាពាក់ព័ន្ធដូចខ្ញុំថាអីចឹង។

ដានី៖ គេប្រកាសឆ្នាំណា ដែលថា វ៉ន វើត គាត់ទៅជាអគ្គមេបញ្ជាការកងទ័ពជើងគោក?

វើត៖ ប្រកាសមុនប្រហែលជា៣-៤ថ្ងៃ។ មុនចាប់គាត់ប្រហែលជា៣ថ្ងៃហ្នឹង។ ប្រកាសហើយ គាត់មិនទៅក្របេះ ទៅម៉ាដងហ្នឹងហើយមកវិញចាប់។

ដានី៖ ឆ្នាំណាហ្នឹង?

វើត៖ ៧៨ ខែ បើមិនខែ មុនចាប់ពូៗប្រហែលជាមួយអាទិត្យហ្នឹង។

ដានី៖ អញ្ចឹងជិតៗហ្នឹងដែរហ្នឹង?

វើត៖ កៀកហ្នឹង។

ដានី៖ ជិតបែកហើយអញ្ចឹង?

វើត៖ បាទ

ដានី៖ ឆ្នាំ៧៨ ចុងឆ្នាំ៧៨ ជិតយួនចូលហើយហ្នឹង?

វើត៖ មុនចាប់មិនដល់មួយអាទិត្យទេ ប្រហែលជាប្រាំថ្ងៃទេ។

ដានី៖ ដល់ពេលគេប្រកាសថាគាត់ជាមេបញ្ជាការកងទ័ពជើងគោកហ្នឹង គាត់ចុះទៅត្រួតពិនិត្យទ័ព?

វីតៈ ចុះទៅត្រួតពិនិត្យហ្នឹង យួនអត់វៃគ្នាមែនៗ ខ្ញុំអីទៅថតរូបថតអីហ្នឹង គាត់ថតទុកជាអនុស្សាវរីយ៍ ពួកនីរសា ពួកកងអន្តរាគមន៍អីទាំងអស់ៗ យួនឆ្លងមកមិនកើតទេ កុំអីមកដល់ក្រចេះយូរហើយ ប៉ុន្តែព្រែកទេវវ៉ាជ្រៅ រថក្រោះចុះមកមិនកើតៗ ហើយបានយន្តហោះជួយអន្តរាគមន៍ បានតា មុត ហ្នឹង ឲ្យយន្តហោះជួយទំលាក់ អាស្លាបកាត់ទៅឆេះ អាស្លាបកាត់ហ្នឹងមួយទៀតធ្លាក់ ទៅបួនគ្រឿងហ្នឹង អាប្រដេញ ហៅពីថ្ងៃបុកមុនដំបូងថ្ងៃ១១ ខែតុលានោះ អាប្រដេញគេចុះនៅលាវមួយបាត់ហើយហ្នឹង មកភ្នំពេញវិញតែមួយហ្នឹង តែមួយអី ដូចអត់ទៅទាំងពីរកាលហ្នុងៗ

ដានីៈ ចុះកាលមុន វ៉ន វីត ត្រូវបានគេប្រកាសតែងតាំង ចុះកាលពីមុនអ្នកណាគេជាអគ្គសេនាធិការ?

វីតៈ អគ្គសេនាធិការអ៊ី សុន សេន ។

ដានីៈ ចុះដល់ពេលគេប្រកាសអញ្ចឹង សុន សេន គាត់ធ្វើអីវិញទៅ?

វីតៈ បើតាមខ្ញុំដឹងផ្ទៃក្នុងខាងលើកាលជំនាន់ហ្នឹងអត់ទុកចិត្តគ្នាៗ

ដានីៈ អត់ទុកចិត្ត សុន សេន ទេ?

វីតៈ អត់ទុកចិត្ត គាត់ទៅនៅសួង ដូចជាគាត់នៅក្នុងផ្ទះ គ្រាន់តែមានមុខថាអគ្គសេនាធិការតែឈ្មោះ ការចាត់ចែងអី លើអ៊ំមុត ហើយនិងលើខ្មោចអ៊ំម៉េតៗ

ដានីៈ តែពីរនាក់ហ្នឹងឯងទេអញ្ចឹង?

វីតៈ អ៊ំម៉េត គាត់ខាងជើងអាកាសហ្នឹង គាត់ចាត់ចែងរួមជំនួស សុន សេន ខ្ញុំដឹងព្រោះគ្រាប់ត្រូវទៅស៊ីញ៉េយកពី... អ៊ំខៀវ អត់មានសិទ្ធិដែរៗ

ដានីៈ អញ្ចឹង តាខៀវ គេចាប់លែងទុកចិត្តគាត់ពីឆ្នាំណា?

វីតៈ មុនអាពេលយួនបុក ។

ដានីៈ យួនបុកឆ្នាំចិតប៉ុន្មាន?

វីតៈ ចុង៧៧ ៗ

ដានីៈ ចុង៧៧ហើយ? ពេលយួនបុកទៅគាត់នៅតែជាអគ្គមេសេនាធិការ ប៉ុន្តែគាត់ឈរជើងនៅក្រសួងទេ?

វីតៈ មើលអាចជំនាន់ចាប់អ៊ំណាត កាលហ្នឹងខាងអ៊ំខៀវ ចាប់អ៊ំណាតមួយទៀតៗ

ដានីៈ តាណាត?

វីតៈ ណាតហ្នឹងកងពល៧០៣ ហ្វេ ៦០៣មជ្ឈឹមដែរ ណាតហ្នុងនៅកំពង់ចាមជាមួយៗ

ដានី៖ គេចាប់នោះមកគេអត់ទុកចិត្តតាខៀវ ។

វើត៖ ក្រោយមកបាន បង ពិន នៅកងពលហ្នឹង ហើគ្រោះថ្នាក់បងពិនហ្នឹងយួនបាញ់ស្លាប់ទៀត ។

ដានី៖ ហើយតាមុត គាត់ទៅខាងហ្នឹងតាំងពីអង្កាល់?

វើត៖ គាត់ទៅម៉ាយួនចូលមួយភ្លែតហ្នឹង គាត់ទៅតែមួយភ្លែតហ្នឹងទេ អត់ទៅយូរទេ ទៅគ្រាន់តែពិនិត្យសមរភូមិហើយគាត់មកវិញ មកភ្នំពេញ គាត់គ្រាន់តែទៅមួយភ្លែតៗ ។

ដានី៖ ប៉ុន្តែសិទ្ធិកងទ័ព តាខៀវ អត់សូវទុកចិត្តទៅ សិទ្ធិកងទ័ពនៅតែពីរនាក់នោះទេ នៅលើតាម៉ុត ហើយនឹងតាមុត? ដូចថាយើងស៊ីញ៉េ បើកអីមានតែពីរនាក់ហ្នឹងទេ?

វើត៖ បើកសំភារៈពីកន្លែងរដ្ឋ ទៅអគ្គសេនាធិការ តាមុត គាត់មានសិទ្ធិ ។

ដានី៖ តាមុតអ្នកមានសិទ្ធិ?

វើត៖ បាទ! ដូចទៅយកឃ្លាំង ឥឡូវសម្ភារៈ កាំភ្លើងអីៗ តាមុតគាត់មានសិទ្ធិ ។

ដានី៖ ដល់ពេលដែលគេថាហៅឡើងយន្តហោះ១១នាក់អីហ្នឹង តាមុត គាត់ទៅដែរ?

វើត៖ អឹមុត អត់បានទៅទេ ។

ដានី៖ ពេលណាដែលគេប្រជុំ? ដែលថាប្រជុំ?

វើត៖ អឹមុត ពេលដែលឡើងយន្តហោះ អឹមុត ឃើញបើកឡានទៅដើង មកស៊ីងត្រែង មិនដឹងមកដល់ស៊ីងត្រែង ឬមកត្រឹមសំបូរទេ ឃើញឡានគាត់មកដើង ។

ដានី៖ គាត់អត់បានជួបគ្នាទេ ពេលហ្នឹងនោះ?

វើត៖ អត់បានជួបគ្នាទេ ។

ដានី៖ ពេលគេហៅ១១នាក់ឡើងយន្តហោះ តាមុត បើកឡានទៅខាងស៊ីងត្រែង? ហើយរយៈពេលប៉ុន្មានបានគាត់ត្រឡប់មកវិញ?

វើត៖ ពេលហ្នុងខ្ញុំទៅលេងស៊ីងត្រែងដែរ ។ ដល់អញ្ចឹងខ្ញុំអត់ដឹង ពួកខ្ញុំពីរឡាននាំគ្នាទៅលេង អាងមេទៅរៀនហើយនោះ ទ័ពរ៉ៃអីរ៉ៃទៅ ខ្ញុំទៅរកនឹកឃើញបានម្ហូបបានអីពីនោះមក ។

ដានី៖ ប៉ុន្មានថ្ងៃបានមកវិញ?

វើត៖ ខ្ញុំទៅដេកមួយយប់ ។

ដានី៖ ដេកមួយយប់បានមកវិញ?

វើត៖ ខ្ញុំដេកនៅលំដាត់ហ្នឹង ដេកកន្លែងពូរឿន នៅ ។

ដានី៖ កន្លែង តា០៥ នៅ?

វើត: ៨០១ ហើ៩២០អីនៅហ្នឹង ពូឿ្រន គាត់នៅរតនគីរី ប៉ុន្តែមន្ទីរគាត់នៅជិតផ្សារហ្នឹងមួយ ដែរកន្លែង៩២០ណា ។ ទៅលេងកន្លែងកងពលដូចគ្នាហ្នឹង មកគាត់ឲ្យមួបសាច់ងៀតដាក់ បាវមកការុងមកហ្នឹង មកដល់កន្លែងវិញលឺប្រកាសថាមេក្បត់គ្រប់គ្នាហ្នឹង ឆោរឡោទៅ ។

ដានី: ពូទៅនោះដេកមួយយប់ហើយ ត្រឡប់មកដល់វិញគេប្រជុំប្រកាស?

វើត: ស្អែកឡើងហៅប្រជុំ ។

ដានី: ដេកមួយយប់មកវិញបានមួយយប់ទៀតបានគេហៅប្រជុំ?

វើត: មកដល់ហ្នឹងដេកមួយយប់ ។ ស្អែកឡើងហៅប្រជុំ កំលាំងមន្ទីរទាំងអស់ កន្លែងមន្ទីរខ្ញុំ ប៉ុន្មានរយ ទាំងពេទ្យ, ខាងការពស់ឡាន នៅឃ្លាំង មន្ទីរនីរសារទាំងអស់ហ្នឹង កងអន្តរា គមន៍អត់បានមកចូលប្រជុំ ព្រោះនៅវ៉ៃ ហៅកំលាំងមន្ទីរទាំងអស់ ឲ្យធំៗទៅវ៉ៃយួន តូចៗឯងដឹកសម្ភារៈចេញ ព្រោះយួនចូល វ៉ាកៀកមែនទែន ។

ដានី: ពីណាអ្នកប្រជុំហ្នឹង?

វើត: ហ្នឹងអ៊ំមុត ប្រជុំមួយភ្លែតៗ គាត់ទៅបាត់ទៀតហើយ គាត់មកភ្នំពេញវិញ ។

ដានី: កាលនោះតាមុត គាត់មកម្នាក់ឯងទេ?

វើត: មាននីរសារគាត់ ពួកសារទូរលេខគាត់មាន មានអាធី មានគង់ ទៅស្លាប់នៅកំពង់សោម អស់ហើយពួកហ្នឹង ។

ដានី: ប៉ុន្តែអ្នកដែលធំៗដូចគាត់មានតែគាត់ម្នាក់ទេ ។

វើត: មានតែគាត់ម្នាក់ ។

ដានី: មានតែ មាស មុត មួយទេ ។

វើត: បាទ ។

ដានី: មកគាត់ប្រជុំ គាត់ប្រាប់ថាម៉េច?

វើត : គាត់ប្រាប់ថា អែងអាធំៗទៅវ៉ៃយួន នេះមេកងពលឯងនេះ មានញ៉ាន់ មានអីនេះ រៀបថ្មី មិនទាន់បាននិយាយអីច្រើន និយាយប៉ុន្មានម៉ាត់ហ្នឹង គាត់ដូចជាប្រញាប់ ដូចស្វាស្វន់ ។

ដានី: ហើយគាត់ថាមេកងពលយើងដែលជិះយន្តហោះទៅថាម៉េច?

វើត: មេឯងក្បត់ហើយ ។

ដានី: ចុះយើងអត់មានតវ៉ាអីជាមួយគាត់ទេ?

វើត: អត់ហ៊ានទេ ។

ដានី៖ ប៉ុន្តែថាមេក្បត់ហ្នឹង ។ ក្រែង រុំ ហ្នឹងត្រូវជាក្មួយគាត់បង្កើត?

វើត៖ ក្មួយម៉េច បើគាត់ថាក្មួយគាត់ក្បត់គាត់ដែរ ។

ដានី៖ ថាក្មួយគាត់ក្បត់គាត់ដែរ គាត់និយាយអញ្ចឹងដែរ?

វើត៖ ...យើងនិយាយខ្លីដែលទេ មកពីយួនចូលលឿនពេក យើងអត់វ៉ៃយួន ។ អ៊ំមុត បើនៅតែបន្តិចទៀត ក៏គេវ៉ៃចោលដូចតែគ្នាដែរ ខ្ញុំនិយាយមួយម៉ាត់ យើងអត់វ៉ៃយួន យួនចូលហើយ ។

ដានី៖ បាទ! ហើយចុះលោកពូ ខ្ញុំធ្លាប់លឺដូចថាខាង តាទិត គាត់ធ្លាប់មានមកផ្លាស់ពីខាងតំបន់ ១៣នេះ មកកាន់តំបន់ក្រចេះមួយរយៈហើយបានមកបាត់ដំបងប្អត់?

វើត ៖ អ៊ំទិត?

ដានី៖ បាទ ។

វើត៖ អត់ទេ ។

ដានី៖ អត់ដែលឃើញគាត់ទៅទេ?

វើត៖ អត់ទេ អ៊ំទិត គឺអត់ទេ គាត់មនុស្សស្លូតណាស់ និយាយពីអ៊ំទិត គាត់អត់មានពាក់ព័ន្ធក្នុងនិយាយរួមគាត់ដូចថាអត់ មនុស្សអត់មាន និយាយរួមអ៊ំទិត គាត់ស្លូត ។ គាត់អ្នកចេះអាចារ្យដូច អ៊ំសាន អ៊ីចឹង ។ អ៊ំសាន សុទ្ធអ្នកស្លូតគាត់អ្នកចេះ អត់មានប៉ះពាល់អីប្រជាជន និយាយមួយម៉ាត់ កងទ័ពអីឃើញទៅ បាយទឹកអីគាត់គិតគូរណាស់ ។

ដានី៖ តាទិត?

វើត៖ តាទិត, អ៊ំសាន ។

ដានី៖ កាលគាត់នៅគិរីវង្ស?

វើត៖ កាលគាត់នៅគិរីវង្ស គាត់រៀបចំបន្ទែបង្ការ យើងមករកគាត់ គាត់ឲ្យ គាត់រៀបចំឲ្យទៅជ្រូក មាន់ ក្នុងមន្ទីររបស់គាត់

ដានី៖ ចុះ មាស មុត ស្គាល់លោកពូទេ? តាមុត?

វើត៖ អាចអត់ស្គាល់ទេ ។ ព្រោះឥឡូវចាស់ ខ្ញុំក៏ចាស់ គាត់ក៏ចាស់ ។ បើដឹងគាត់ស្គាល់តែ រុំ ហើយ ចិន ហ្នឹងទេ ។ ព្រោះជំនាន់ហ្នឹងខ្ញុំនៅតូច ចិតក្បាលដូងនៅកុមារ អាយុដប់បួនដប់ប្រាំ ។ ឥឡូវខ្ញុំក៏ភ្លេចគាត់ គាត់ក៏ភ្លេចខ្ញុំ ។ សូម្បីតែ អៀង ផាន ឧត្តមសេនីយ៍ អៀង ផាន រាល់ថ្ងៃហ្នឹងគាត់មិនស្គាល់ខ្ញុំផង ។

ដានី៖ អៀង ផាន គាត់នៅណាដែរកាលហ្នឹង?

វើត៖ កាលហ្នុងនៅជាមួយពូវ៉ែន និយាយថាធ្លាប់នៅនីរសាជាមួយគ្នាហ្នឹង ។

ដានី៖ កាលហ្នឹង អៀង ដាត នៅឋានៈប្រហែលៗពូដែរ?

វើត៖ កាលហ្នឹងគាត់អនុសេនាធំ ខ្ញុំនៅមន្ទីរដូចគ្នា ប្រធានមន្ទីរ គ្រាន់តែគាត់អនុសេនាធំកងពិសេស ខ្ញុំនៅមន្ទីរឋានៈប្រជុំបក្សអីជាមួយគ្នាអីចឹង ឥឡូវអត់ស្គាល់គ្នាណា៎ កាលជំនាន់មកនៅប្រកនេះ គាត់ស្គាល់ ដល់ឥឡូវទៅប្រជុំថ្ងៃមុនអត់ស្គាល់គ្នា ។

ដានី៖ លោកពូ ឥឡូវនៅធ្វើទាហានដែរឥឡូវ?

វើត៖ បាទ! នៅ ។

ដានី៖ សក្តិប៉ុន្មានដែរលោកពូឥឡូវ?

វើត៖ អនុសេនីយ៍ទោ សក្តិ២ ។

ដានី៖ តូចជាងគាត់ច្រើនពេកបានគាត់អត់ស្គាល់?

វើត៖ តូច ។ ងងឹតផងមើលគាត់មិនស្គាល់ មិនមែនថាចង់ស្គាល់អី គ្រាន់តែថាដូចតែគាត់ម៉េចហ៊ានទៅជិតបើលេងផ្កាយ២ ហើយសក្តិ២ ខុសគ្នាច្រើន... ។

ដានី៖ ឆ្ងាយ! គាត់ធំទៅជាឯកឧត្តម ឧត្តមសេនីយ៍ហើយ លោកពូនៅតូចអត់ហ៊ានទៅជិតគេហេ៎?

វើត៖ បាទ ។

ដានី៖ កាលពីមុនអតីតភាពយើងចេះតែ ។

វើត៖ ឥឡូវមានច្បាប់ ខ្វាចច្បាប់អត់ហ៊ានទេ ។

ដានី៖ អញ្ចឹងលោកចង់ជំរាបសួរលោកពូ ក្រោយពេលបន្ទាប់ពី តាមុត គាត់ថាអាធំៗទៅវៀឃួន អាក្រោយៗដឹកសម្ភារៈ យ៉ាងម៉េចទៀតទៅ បន្ទាប់ពីហ្នឹង?

វើត៖ បន្ទាប់មកខ្ញុំទៅវៀ ។ ខ្ញុំទៅម្តុំកន្ទួត អូរដាយើងហ្នឹង ហួសព្រលានហ្នឹង ឲ្យទៅចាំហ្នុង ចាត់កំលាំងខ្ញុំទៅ៧០នាក់ ៧០នាក់ហ្នឹង បងញ៉ាន់ ចេះតែបញ្ជាពីក្រោយ ធ្វើម៉េចឲ្យរថក្រោះមកដាន់កាណុង ដល់ដាន់កាណុង ខ្ញុំថាបើចំ ខ្ញុំអត់កើតទេ ខ្ញុំថាឥឡូវយើងបំបែកគ្នាកំលាំងមួយកំណាត់ហ្នឹងពាក់ជាមួយពូនីម ។ ពូនីម គាត់នៅហ្នឹងដែរនោះ ពូនីម ផ្ទាល់ គាត់ដាច់ខាតអត់សុខចិត្តរត់មកលិចទន្លេទេ សុខចិត្តនៅ... គាត់នៅជើងផ្លូវ ខ្ញុំនៅត្បូងផ្លូវ ។ ដល់អញ្ចឹងអាក្រោះមកផ្លូងមិនមកដល់ព្រលាន សាំងនៅព្រលានក៏ដឹកចេញមិនបានដែរ មិនឆុបឆេះ ។ អញ្ចឹងខ្ញុំឆែលទៅរកាកណ្តាលនោះ គាត់វាលស្រែព្វកខ្ញុំ៧០នាក់គាត់ទៅមាត់ទន្លេនោះ ទៅដល់រការកណ្តាល ទៅដល់ហ្នឹងមួយយប់ឲ្យទៅត្រៀមហ្នឹង ។ ត្រៀមហ្នឹង

ម៉ោងបួនភ្លឺយើងឡើងឲ្យអ្នកចង្រ្កានបាយ ប្រជាជននៅមាត់ទន្លេពេញទាំងអស់ ទូកអីនៅហ្នឹង ខ្ញុំនៅឆ្ងាយពីមាត់ទន្លេប្រហែលថ្នល់ហ្នឹងឯង ខ្សែត្រៀមដាក់ហ្នឹង ឲ្យមកប្រាប់អ្នកចង្រ្កានបាយម៉ោង៥កន្លះ ម៉ោង៦ ឲ្យរៀបបាយយកទៅនោះ ម៉ោង៦ធ្វើម៉េចឲ្យទៅដល់កន្លែងខ្សែត្រៀម រៀបចំចង្រ្កានបាយ ហើយគេអូពេលណាគេយកឃួនធ្វើម៉េចឲ្យជាន់កាណុង។ គ្រាន់តែខ្ញុំមកដល់ដំបូកអញ្ចឹង ចុះបីជួរបណ្ដោយ អូនឯង មកពីនោះ៣ជួរបណ្ដោយអីចឹង គ្រាន់តែប៉ះគ្រង់សេមួយដីង។ ផ្ទុំបីគ្រឿង ៣កាណុងហ្នឹង បំបែកបីជួរទទឹងឆ្វាច់ហក់ចូលគ្រង់សេ ហ្នឹងមិនបាក់៣គ្រង់សេបាត់ នាំគ្នាផ្អើលឆុល អត់មានទេ រត់កាត់ស្រូវ។ ទៅដល់ប្រជាជនគាត់លិចទូកអស់រលីង មាត់ទន្លេគាត់លិចទូក ខ្ញុំធ្លាក់ទឹកបានឫស្សីរងថ្នាំ ធ្លាក់ទឹកទន្លេទៅ កណ្ដាលទន្លេ កាលហ្នុងបន់តែអាយុ។

ដានី: ដល់ពេលអញ្ចឹងទៅលោកពូយ៉ាងម៉េចទៀតទៅ យើងរត់អីមកតាមណា។?

វើត: ដល់រត់មក ពួកខ្ញុំហ្នឹងម៉ោង១២ខ្ញុំហែលមកដល់ត្រើយលិច។ ទន្លេជិតទេ តែដល់ទន្លេសាត់ទៅក្រោម។ ដល់អញ្ចឹងបានឫស្សីខ្លះហែល និយាយរួមទៅភាគច្រើនហែលលិចស្លាប់ហើយមកដល់ត្រើយលិច ពួកត្រើយលិចមិនឲ្យឡើងទៀតប្រាំងទៀត គេថាអ្នកនៅឯណានៅហ្នឹង ពួកកណ្ដាលនេះ អញ្ចឹងទៅម៉ោង១២បាន បងញ៉ាន់ គាត់ចរចានៅព្រែកប្រសប់បងញ៉ាន់ គាត់នៅហ្នឹង គាត់និយាយជាមួយគេហ្នឹងសុំឲ្យពួកខ្ញុំហ្នឹងឡើងទៅលើមាត់ប្រាំង។ ខ្ញុំឡើងទៅលើមាត់ប្រាំងទៅក៏រៀបកាំភ្លើងបើកថ្មីគេទាំងអស់ ព្រោះកាំភ្លើងនៅពីរកប៉ាល់ហ្នឹងថ្មីថែស មិនទាន់បានដឹកចេញជញ្ជូនចេញទេ កាំភ្លើងធំមួយកប៉ាល់ ភ្លើងអាកាមួយកប៉ាល់ គ្រាប់នៅលើកប៉ាល់ ពន្លិចចោលហ្នឹងបីងព្រែកប្រសប់ហ្នឹង ពួកខ្ញុំហ្នឹងលឺថា តាខៀវជាប់នៅស្នួលហ្នឹង។

ដានី: តាខៀវ ជាប់នៅស្នួល?

វើត: បាទ តាខៀវ ជាប់នៅស្នួល ពួកខ្ញុំមកចំការកៅស៊ូយើង។

ដានី: ចុះតាមុត?

វើត: តាមុត មកនៅកំពង់សោមហើយ។

ដានី: អូរ មកកំពង់សោមវិញហើយ?

វើត: គាត់មកវៃនៅកំពង់សោមវិញ កំពង់សោមបុកខ្ទាំងដែរនោះ។ ដល់អញ្ចឹងពួកខ្ញុំ១១៧ បងញ៉ាន់ មកវៃរំដោះ អ៊ំខៀវ យកទៀត។

ដានី: យើងឆ្លងមកដល់ត្រើយម្ខាងហើយវៃរំដោះយកទៀត?

វើតៈ មកជួយយកគាត់ធ្វើម៉េចឲ្យបានដល់ចំការនៅស្ទឹងត្រង់ មកជួយបានអ៊ំខៀវ ពួកខាង ទ័ព គាត់ ខាងអ៊ំពក មកជួយ ។

ដានីៈ មកដល់ស្រុកស្ទឹងត្រង់?

វើតៈ បាទ! បានយក អ៊ំខៀវ មកនៅហ្នឹង នៅជាមួយអ៊ំ ពក មក ។

ដានីៈ រួចទៅលោកពូម៉េចទៀតទៅ? កងពលលោកពូ?

វើតៈ ខ្ញុំនៅជាមួយ បងញ៉ាន់ រហូត ។ នៅឡើងមកដងរែកអីហ្នឹង ។ ខ្ញុំលឺដំណឹងថាម្ដាយ ម្ដាយខ្ញុំគាត់មកនៅហ្នឹង ដល់ម្ដាយខ្ញុំនៅហ្នឹង ខ្ញុំសុំមកពីនោះ ជិះឡានដឹកគ្រាប់មក ដល់ឡានដឹកគ្រាប់មកខ្ញុំឡើងវាខុស ។ និយាយរំលងបន្តិចខាងអ៊ំខៀវ ប៉ុន្តែខ្ញុំនឹង អ៊ំខៀវ គាត់ស្គាល់គ្នា ។

ដានីៈ ខៀវ, សុន សេន ហ្នឹងហ៎?

វើតៈ ហ្នឹងហើយ ។ គាត់ធ្លាប់នៅនីរសាក្រុងជាមួយគ្នា ។ ដល់ពេលអញ្ចឹងទៅនិយាយប្រវត្តិរឿងចាស់បន្តិចទៅចុះ កុំឲ្យមានទោស ទោសក៏ទោសទៅ ។ ដល់ពេលអញ្ចឹងទៅគាត់ស្គាល់ខ្ញុំ ឲ្យខ្ញុំមួយក្រុម កំលាំងការពារបងញ៉ាន់ ហ្នឹងគឺនៅមន្ទីរហ្នឹង ។ ដល់នៅមន្ទី គាត់ឡើងមកខែ៤ អ៊ំខៀវ ឡើងមកដងរែកគាត់ឡើងមកខែ៤ ពួកខ្ញុំឡើងមកខែ៦ ។ ដល់មកខែ៦មកឆ្លងផ្លូវឆែប សាលាថ្លាបរិវ៉ាត់ហ្នឹង ឆ្លងផ្លូវជាំក្សាន្តហ្នឹង ដល់ឡើងទៅវាមិនចំកន្លែងគាត់ទន្លេល្ពៅ កន្លែង១០០១នោះទេ ឡើងមកចំប្រកគា១០០៣ ពួកខ្ញុំ៦០០នាក់ហ្នឹង គាចោទថាឲ្យតែពួកហ្នឹងឡើងទៅដល់លើចាប់ពួកហ្នឹងចូលយួន ពួកខ្ញុំ៦០០ហ្នឹងដើរកាត់មកភ្នំឆ័ត្រ មកដល់ហ្នឹងជួបបង យន យើងនៅភ្នំឆ័ត្រហ្នឹង ខ្មោច បង យន ។

ដានីៈ យន កងពល៥១៩?

វើតៈ ៥១៩ហ្នឹង ជួបបងយន គាត់ថាទៅណាហ្នឹង? ធ្លាប់ស្គាល់តាំងពីជំនាន់ ។ សុំទៅលេងម៉ែនៅតាង៉ុក ។

ដានីៈ នៅណា?

វើតៈ នៅតាង៉ុក ជំរំតាង៉ុក តែមិនមែនជំរំទេ អត់ទាន់មានជំរំទេ ម៉ែខ្ញុំស្លាប់មាត់អូរនេះទេ ដល់អីចឹងទៅ គាត់ថាឯងជិះអីទៅ ខ្ញុំថាជិះឡានដឹកគ្រាប់ក៏បានដែរ ខ្ញុំក៏ជិះឡានដឹកគ្រាប់មកគីឡូ១៣ហ្នឹង ដល់អីចឹងទៅជិះឡានដឹកគ្រាប់មក ដល់មកដល់ហើយមានអីទៅវិញ ដល់ហើយសុទ្ធតែអ្នកស្គាល់ៗនៅនេះ នោះសាច់ឈាមៗ អត់ឲ្យទៅវិញ បានតា ខៀវ ហ្នឹងប្រាប់មក តាកិន នេះ ។ គាត់ធ្លាប់ស្គាល់ខ្ញុំអីចឹងឲ្យនៅជាមួយ តាកិន ហ្នឹងទៅ ។

ដានីៈ តាកិន គាត់ខាងអីគេហ្នឹងកងពល?

| | |
|---|---|
| វើតៈ | កាលហ្នឹងគាត់គណៈសមរភូមិ តែកាលហ្នឹងមិនទាន់រៀបគណៈសមរភូមិទេ នៅ៨២, ឆ្នាំ ៨១ហ្នឹងហើយ នៅកងពល៣២០ ក៏ខ្ញុំនៅទៅបានកើតថាយាយហ្នឹងក៏គាត់ថាស្គាល់ខ្ញុំដែរ យាយហ្នឹង បាននៅជាមួយគាត់ ក៏ការទៅ ។ |
| ដានីៈ | ហើយដល់ពេលមកដល់អីចឹង ហើយអ៊ីក៏ដាច់ពីតាញ៉ាន់អីទៅ? |
| វើតៈ | ខ្ញុំដាច់ពីនោះមក គ្រាន់តែថាខ្ញុំទៅរៀន ជួបគាត់នៅកន្ទែង ។ |
| ដានីៈ | តែចូលមកនៅជាមួយកងពល៣២០វិញ? |
| វើតៈ | មកនៅជាមួយបងរម្យ ជាមួយពូវិញ ក៏នៅជាប់ ។ |
| ដានីៈ | កងពល៣២០ កើតឆ្នាំណា? |
| វើតៈ | កើតយូរហើយ ឆ្នាំ១៩៨២នោះ ។ |
| ដានីៈ | កើតឆ្នាំ៨២? |
| វើតៈ | មុនមានតែវរសេនាធំទេ ក្រោយមក ៣២០ចាស់វាតែមួយទោល ដល់៨៣មុនយួនបុក ៨៥នេះ ។ ៨៣បានរៀបទៅជា៣២០, ៧០៥, ៩៤៨ខាងបងពុតនេះ ឆ្នាំ៨៣ ។ |
| ដានីៈ | កើតដំបូងគេ? |
| វើតៈ | តែ៣២០មួយទេ ។ |
| ដានីៈ | ហ្នឹងឆ្នាំណា? |
| វើតៈ | ពីឆ្នាំ១៩៧៩មកមានតែ ។ |
| ដានីៈ | ឆ្នាំ៧៩ ដល់ឆ្នាំ៨៣ បង្កើតចេញ ។ |
| វើតៈ | ៣២០វាកើតមុន៨៣ វា៨១-៨២វានៅក្នុងវរសេនាធំនៅឡើយ ៣២០តែមួយ ដល់៨៣បានរៀបបំបែកទៅជា៣២០ហ្នឹងវាមានមួយ, ៧០៥មួយ, ៩៤៨មួយ វាមាន ៣កងពល ។ |
| ដានីៈ | ៩៤៨ ហើយនិង៧០៥, ៣២០ កាលហ្នឹង៧០៥ឈរនៅណា? |
| វើតៈ | ៧០៥ កំរៀង ខាងបងគង់ ។ |
| ដានីៈ | កំរៀង របស់តាគង់ ។ តាគង់ ធ្វើប្រធាន? |
| វើតៈ | បងគង់ គាត់ប្រធានជាមួយបងជាតិ ។ |
| ដានីៈ | គង់, ជាតិ ។ គង់ ឥឡូវគាត់អភិបាលរងនៅបាត់ដំបង? |
| វើតៈ | បាទ ។ |
| ដានីៈ | ហ្នឹងកងពល? |

វីតៈ ៧០៥ ។

ដានីៈ ជាតិ ហើយនិងគង់ នៅកំរៀង? ដល់ពេលកងពល...?

វ៉ីតៈ ហ្នឹងនិយាយពីរៀបចាស់ រៀបពី៨៣ ចូល៨៤ហើយ ។

ដានីៈ ៨៣-៨៤ ហើយ៩៨៨?

វីតៈ ៩៨៨មានបងពុត មានបងបិន មានវង១ច្រើនទៀត តែរាប់តែមេៗ ។

ដានីៈ ពុត ហើយបិន ឈរនៅណា? ឈរពីចន្លោះពីត្រឹមណាទៅណា?

វីតៈ ហ្នឹងគាត់ទន្លេ ។ គាត់នៅខាងទន្លេសាបនោះ ។

ដានីៈ ទន្លេសាបហ្នឹងខេត្តណា?

វីតៈ សមរភូមិ៩៩នៅទន្លេសាប ក្នុងកងពលមានបងស៊ុត, រ៉ុន នៅ៩៨៨ ។

ដានីៈ កន្លែងភ្នំព្រឹកយើងកងពលប៉ុន្មាន?

វីតៈ ៣២០ ខាងបងរម្យ ។

ដានីៈ ៣២០ តាំងពីសំពៅលូន, ភ្នំព្រឹកហ្នឹង៣២០ទាំងអស់?

វីតៈ បាទ ។

ដានីៈ ហ្នឹងប្រធាន?

វីតៈ ប្រធានបងរម្យ ។ ខ្មោចបងហឿន ហើយនិងបងរម្យ សិទ្ធិស្មើរគ្នា មួយប្រធាននយោបាយ មួយប្រធានដែរ ។

ដានីៈ ហឿន ហើយនិងរម្យ?

វីតៈ បាទ! តាបៃ ។

ដានីៈ តាបៃ នៅនេះ?

វីតៈ បាទ! អភិបាលវង ។ ដល់ក្រោយមកប៉ៃតជាង ចូល៨៥-៨៦-៨៧ទៀតបានរៀបមានមួយកងពលទៀត ៤០៤ ហ្នឹងកងពលអន្តរាគមន៍តូ ។

ដានីៈ អានេះឆ្នាំប៉ែតប៉ុន្មាន?

វីតៈ ៨៦-៨៧រៀបមួយកងពលទៀត ។

ដានីៈ ឆ្នាំ៨៦-៨៧រៀបកងពលថ្មី ។

វីតៈ កងពលថ្មី៤០៤ កងពលអន្តរាគមន៍ពិសេសរបស់ពូកិន ហ្នឹងមានគណៈកងពលច្រើនជុំវិញគាត់ ។

ដានីៈ កងពលអន្តរាគមន៍!

វើតៈ ខ្មោចបងម៉ៅ ។

ដានីៈ ប្រធានពីណាគេប្រធាន?

វើតៈ មានបងម៉ៅ ។

ដានីៈ ឈ្មោះម៉ៅ ។

វើតៈ ម៉ៅ មក៤៣, តារ៉ាត់ គាត់ប្រធានយោធាគាត់នៅជាប់ពូ ។ មកតាខៀវ ឃី នៅកងពលរាល់ថ្ងៃ ហ្នឹងវង់ៗគាត់ ហ្នឹងកងពលអន្តរាគមន៍របស់... ។

ដានីៈ តាបៃ អភិបាលវង ។

វើតៈ អត់ទេ! និយាយខៀវ ឃី នៅជាមួយតាខៀវ មកពីដើងជាមួយតាខៀវ ហ្នឹងគាត់ ៤០៤ ។

ដានីៈ ឈ្មោះអីឃី?

វើតៈ ខៀវ ឃី រាល់ថ្ងៃវរសេនីយ៍ឯក មេបញ្ជាការរងកងពល ។

ដានីៈ នៅណា? កងពលណា?

វើតៈ នៅជាមួយមេខ្ញុំរាល់ថ្ងៃ កងពល៥៣ ជាមួយបងរម្យ ។

ដានីៈ ជាមួយរម្យ កងពល៥៣នៅ... ។

វើតៈ នៅកំប្រង់ ។

ដានីៈ អីចឹងកងពល៤០៤នេះមាន ម៉ៅ, មាន រ៉ាត់, មាន ខៀវ ឃី ។ ៣នាក់ហ្នឹងទេ?

វើតៈ មានវង់ៗទៀត គ្រាន់តែគាត់វរសេនាធំខ្លះ ។

ដានីៈ លោកពូមានថាម៉ិញឈ្មោះកិន?

វើតៈ ពូកិន គាត់គណៈសមរភូមិរួម ។

ដានីៈ អីចឹងទាំងកងពល ទាំង ៩៤៨, ៣២០, ៤០៤, ៧០៥...

វើតៈ ក្រោមការគ្រប់គ្រងរបស់គាត់ទាំងអស់ ក្រោមគ្រប់គ្រងរបស់ពូ កិន ទាំងអស់ ។

ដានីៈ ក្រោមគ្រប់គ្រងរួម កិន ។ កិន នៅណាឥឡូវ?

វើតៈ ពូ គាត់នៅ៣២ ។

ដានីៈ កិន ឈ្មោះគាត់ពេញឈ្មោះអី?

វើតៈ ឈ្មោះកិន ហ្នឹងហើយ នី កិន ។

ដានីៈ នី កិន?

វើតៈ ទីប្រឹក្សាក្រសួងការពារជាតិ តែឥឡូវគាត់ចូលនិវត្តន៍ហើយ ។

ដានី: នី កន ហ្នឹង?

វើត: បាទ! នី កន ហ្នឹងហើយ ប៉ុនគាត់ កិន ទេ ដល់ហើយគេហៅគាត់ នី កន តែឈ្មោះគាត់ពេញមកគេហៅតែ តាកិន ទេ។

ដានី: គេហៅតាកិន ទេ?

វើត: តាកន គេហៅគាត់ក្រៅ ឈ្មោះគាត់ពិតតាកិន។

ដានី: នី កន ហៅ កិន។ នៅស្រុកនេះគេហៅតាកិនៗ?

វើត: ខ្ញុំដឹងតែឈ្មោះគាត់ហៅ កិន ដល់ពេលបងប្អូនប្រជាជនហៅតាកនៗ អីចឹងទៅ។

ដានី: ចុះបន្ទាប់ពីគាត់មានពីណា?

វើត: ពីមុនគណៈសមរភូមិមាន បងសារឿន (៦៣) ស្លាប់ហើយ ស្លាប់តាំងពី៨៨នោះ។

ដានី: ឈ្មោះអីសារឿន?

វើត: សាត សារឿន។

ដានី: សាត សារឿន។

វើត: កាលមុនគណៈសមរភូមិមាន៣នាក់ មានអៀង ដាន, មានតាធីម នៅអូរអន្ទក់ក៏ស្លាប់ដែរ តាធីម គាត់គណៈភស្តុភាហ្នឹង គាត់នៅគណៈអព្រៃ្រួយ៍។

ដានី: តាសាត សារឿន គាត់ស្លាប់ឆ្នាំប៉ែតប៉ុន្មាន?

វើត: ៨៨។

ដានី: ស្លាប់ដោយសារអីគេ?

វើត: គាត់ស្លាប់ដោយសារជំងឺ របួសគាត់សុះសាច់ហើយ។

ដានី: ចាំមើល នី កន (តាកិន), សាត សារឿន ពីណាទៀត?

វើត: អៀង ដាន ហ្នឹង។

ដានី: អៀង ដាន គាត់គណៈសមរភូមិដែរ?

វើត: សមាជិក។

ដានី: ហើយគាត់អត់មានទទួលកងពលណាមួយទេ?

វើត: ដល់ក្រោយមកគាត់ទៅវិញ ៨៣គាត់ទៅវិញ។

ដានី: គាត់ទៅខាងវាលវែងវិញ?

វ៉ើត៖	គាត់ទៅខាងនោះវិញ គាត់មក៨២យូនបុកហ្នឹង គាត់មកជំនួសបានប្រហែលជា២ឆ្នាំ ឆ្នាំ ១៩៨២-១៩៨៣ ពេលរៀបកងពលនេះហើយ បាន៤កងពលនេះគាត់ទៅវិញ ឯណុះបុកខ្លាំង ។

ដានី៖	ទៅវាលវែងវិញ ហើយមួយទៀតឈ្មោះតាអីគេមិញ?

វ៉ើត៖	តាចឹម មកបានខ្មោចបងមិច បង៩៤នៅ៤០៥ កាន់កស្តុកាហ្នឹង សុទ្ធតែសមាជិកកងពលទាំងអស់ហើយ សមាជិកគណៈសមរភូមិ ។

ដានី៖	តាទឹម?

វ៉ើត៖	មិនមែនទេ តាទឹម នៅរាល់ថ្ងៃទេ តាចឹម នៅអូរអន្ទក់ គ្រកូលគាត់មិនដឹងឈ្មោះស្អីទេគាត់ជនជាតិ ។

ដានី៖	តាចឹម សព្វថ្ងៃនៅអូរអន្ទក់?

វ៉ើត៖	ស្លាប់ហើយ ។ បងមិច ក៏ស្លាប់ដែរ បង៩៤ក៏ស្លាប់ដែរបងមិច ហ្នឹងសុទ្ធតែសមាជិក ពូហើយ ។

ដានី៖	មិច ហ្នឹងហៅគាត់ឈ្មោះ៩៤?

វ៉ើត៖	លេខគាត់៩៤ ។ បងចឹមនោះ១៣លេខគាត់ ។

ដានី៖	ស្លាប់ហើយ?

វ៉ើត៖	ស្លាប់ ហ្នឹងសុទ្ធតែគាត់ជំនួសមុខឲ្យគណៈសមរភូមិ ។

ដានី៖	អីចឹងកងពលទាំងអស់មានទីតាំងចាប់ពីកំរៀង មកត្រឹមសំពៅលូន កងពលទាំងអស់?

វ៉ើត៖	បើនិយាយពីកងពលទាំងអស់នេះ គ្រប់គ្រងពីមុនដីធំណាស់ ទៅដល់ម៉ាឡៃ ម៉ាឡៃពីដើមឡើយមានតែតិច ម៉ាក្រវិចទេ ពីដើមឡើយដី២៥០នេះដល់ត្រឹមភូមិសង្កែ ត្រឹមជាប់ភូមិដូងតែម្តង គឺគ្រប់គ្រងពីត្រឹមហ្នឹងមក ពីត្រឹមបឹងត្រកួន ហៅបឹងត្រកួន ពីត្រឹមខាងជើងភ្នំរូងមករហូត មកដល់ដីខាង២៥០ទាំងអស់ ខាងពូកិន ។ ដោយឡែក ឥឡូវកាត់ទៅម៉ាឡៃ បឹងបេង ភ្នំរូង កាត់ទៅម៉ាឡៃ ពីមុនបឹងបេងនេះដីនេះទេ ខាងម៉ាឡៃដីតិចទេ ពីមុនដីតិចទេ មួយក្រវិច ត្រឹមប្រកម៉ាឡៃតិច ហើយ៩៣តិច ហើយនិងខ្លាងរាប់តិចហ្នឹង ។ ២៥០ហ្នឹងដីធំណាស់ទល់បរិល ។

ដានី៖	ហ្នឹងគេហៅ២៥០?

វ៉ើត៖	បាទ ។

ដានី៖	តំបន់២៥០?

វើតៈ បាទ ។

ដានីៈ មិនមែនតំបន់៣២ទេ?

វើតៈ ៣២ហ្នឹង តែគណៈសមរភូមិ២៥០ ។ ៣២ហ្នឹងកន្លែងមន្ទីរគាត់ទេ ភ្នំមន្ទីរគាត់ ។

ដានីៈ សមរភូមិ២៥០?

វើតៈ បាទ! ជំនាន់នោះដីធំ ។

ដានីៈ នៅម៉ាឡៃមានប៉ុន្មានកងពល?

វើតៈ ម៉ាឡៃមានតែមួយកងពល បងភា៣៨៥០ហ្នឹងមួយ មួយកងពល ។

ដានីៈ ពីហ្នឹងទៅដល់កំរៀង ចុះទៅប៉ៃលិន?

វើតៈ ប៉ៃលិនមានតែមួយកងពល៤១៥ហ្នឹង ។

ដានីៈ ៤១៥មួយទេ?

វើតៈ បាទ! មានតែ៣វរសេនាធំហ្នឹង វ១៥, ១៦, ១៧ដែរ យកចាស់ពីនោះមកដាក់ ។

ដានីៈ យកពីណាមក?

វើតៈ យកលេខពីក្រចេះមកដាក់កងពល ។

ដានីៈ ជាពិសេសទោកងពលនៅប៉ៃលិនហ្នឹងភាគច្រើនកងពល១១៧ចាស់?

វើតៈ ១១៧ចាស់ទាំងអស់ ។

ដានីៈ ១១៧ចាស់នៅក្រចេះ?

វើតៈ តាខេ ស្លាប់អស់ហើយ និយាយកងពលចាស់ពីនោះមក វរសេនាធំពីនោះមកនៅប៉ៃលិន ទាំងអស់ ។

ដានីៈ ម៉េចបានតាញ៉ាន់ គាត់អត់នៅហ្នឹង?

វើតៈ បងញ៉ាន់ ដាច់ដោយឡែកដូចថាខាងនេះអត់ពេញចិត្តអ្នកថ្មី អ្នកចាស់បំបែកចែកកំលាំងគ្នា ឃើញបងឈុត មកអីចឹង បងឈុត មកស្លាប់តាមផ្លូវអីចឹង បំបែកកំលាំងដណ្តើមទ័ពគ្នា ជំនាន់យើង៧៩...។

ដានីៈ ចុះអ៊ី ឈាន ម៉េចបានមកនេះ?

វើតៈ ឈាន គាត់អត់មានពាក់ព័ន្ធអីជាមួយកងទ័ព ។ បងឈានគាត់នៅខាងភ្ញៀវ ដល់អីចឹង ដូចគាត់អត្តចរិកល្អ សុខចិត្តនៅជាមួយគាត់ទៅ គាត់ដោះស្រាយស្បៀង ឬក៏អីៗ គាត់ ដោះស្រាយបាន ។

ដានីៈ កាលហ្នឹងកាលកងពល៤១៥ហ្នឹង គឺអតីតរបស់កងពល ភាគច្រើនកងពល១១៧?

វើត៖ សឹងមួយរយភាគរយរបស់១១៧ចាស់ទាំងអស់ ។

ដានី៖ មកដល់ហ្នឹងភ្លាម អ៊ី ឈាន គាត់ធ្វើប្រធាន ឬក៏មានអ្នកផ្សេងមុនគាត់?

វើត៖ អត់មានអ្នកណា បងឈាន គាត់គ្រប់គ្រងផ្ទាល់ អត់មានអ្នកណាប្រធានទេ ។

ដានី៖ អ៊ី ឈាន គាត់ធ្វើប្រធាន ហើយពីណាអនុ គាត់ពីណា?

វើត៖ អនុ គាត់កាលហ្នុងមានច្រើន ខ្ញុំអត់បានសួរដឹង ដល់គាត់រៀបថ្មីគ្នាគាត់ ខ្ញុំភ្លាប់អត់បាន ។

ដានី៖ នឹម គាត់បានមកហ្នឹងដែរ?

វើត៖ នឹម អត់ទេ នឹម នៅខាងនោះ ។

ដានី៖ ឈុត ក៏អត់បាន?

វើត៖ ឈុត ស្លាប់ ។ ស្លាប់ម្តុំណាទេ យួនបាញ់ ។

ដានី៖ អីចឹងត្រឹមតែវរសេនាធំ, វរសេនាតូចទេទៅ ។

វើត៖ ទៅនេះទៅតែកូនទ័ព, វរសេនាតូចមួយចំនួន ដល់អីចឹងអ្នកអនុសេនាធំខ្លះទៅ ប្រធានឲ្យឡើងវរសេនាធំ... ។

ដានី៖ លោកពូម៉ិញមានប្រសាសន៍ថា ឪពុករបស់លោកពូត្រូវជាមិត្តភក្តិរបស់ជាមួយ តាខៀវដែរ?

វើត៖ បាទ! គាត់ធ្លាប់នៅគ្នា គាត់ចាស់ៗ ខ្ញុំមិនសូវយល់ដែរ ។

ដានី៖ ឪពុករបស់លោកពូឈ្មោះ ឈុំ ជី ហ្នឹង?

វើត៖ បាទ ។

ដានី៖ អីចឹងគាត់នៅជាមួយគ្នាតាំងពីអន្កាល់?

វើត៖ គាត់នៅពីជំនាន់គាត់ ខ្ញុំអត់ដឹងដែរ ប៉ុន្តែខ្ញុំពីដើមគាត់សូហ៊្វ័រឡានរបស់ឥណទានជាតិ ។

ដានី៖ សូហ៊្វ័រឡានពីណា?

វើត៖ សូហ៊្វ័រឡានឥណទានជាតិ ពីដើម ពីសង្គម ហៅថាបញ្ញើជាតិខ្ញុំ ប៉ុន្តែខ្ញុំសូហ៊្វ័រឡានឥណទានជាតិ ។

ដានី៖ សូហ៊្វ័រឡានយ៉ាងម៉េចខ្ញុំស្តាប់អត់បាន?

វើត៖ សូហ៊្វ័រឡាន អ្នកបើកឡាន ។

ដានី៖ បើកឡានឲ្យពីណាគេ?

វើត៖ មិនដឹងខ្ញុំអត់យល់ ។

ដានី៖ ប៉ុន្តែសូហ៊្វ័រឡានម៉ិញលោកពូមានប្រសាសន៍?

វើតៈ នៅឥណទានជាតិ ។

ដានីៈ អ៊ូ! សូហ្វ័រឡានឥណទានជាតិ ។

វើតៈ បាទ! ពីសង្គម ។

ដានីៈ ជាមួយតាខៀវ សុន សេនហ្នឹង?

វើតៈ មិនដឹង ខ្ញុំអត់ដឹងទេ ដល់គាត់មករាប់ប្រវត្តិជាប់ស្រឡាយបានជាខ្ញុំរស់ដល់ថ្ងៃនេះ ។

ដានីៈ តាខៀវ គាត់និយាយប្រាប់?

វើតៈ បាទ ។

ដានីៈ ប្អូននិយាយប្រាប់តាខៀវ?

វើតៈ អ៊ំខៀវ ធម្មតាប្រវត្តិរូបដូចខ្ញុំអ៊ីចឹង ធម្មតាខ្ញុំលើកបាយទឹកឲ្យគាត់ មិនរកប្រវត្តិរូបមុន នៅជាមួយអ្នកដឹកនាំទាល់តែអ្នកហ្នឹងប្រវត្តិរូបច្បាស់ណាស់ បានចេញចូលបាន ។

ដានីៈ លោកពូមានប្រសាសន៍មុនហ្នឹងថា ពេលដែលលោកពូទៅខាងច្រក១០៣ ចូលទៅជួបតាម៉ុក អ៊ីចឹងអី?

វើតៈ ១០០៣?

ដានីៈ ១០០៣ ។

វើតៈ ហ្នឹងខ្ញុំនិយាយពីឆ្នាំ៨០ទេ ដែលយើងទៅហ្នុង គាត់ទៅខែ៤ ខ្ញុំទៅខែ៦ ពួកខ្ញុំត្រូវឃើតដល់អ៊ីចឹងខាងតា មិនមែនគាត់ថាផ្ទាល់ទេព្រោះតែយើងឡើងទៅលើភ្នំត្រូវឃាត់ទ័ពទាំងអស់ អត់ឲ្យមក អាណាមេៗមិនវៃចោល ដល់អ៊ីចឹងអ្នកនីរសានៅជាមួយគាត់គេមកប្រាប់ថា តែឡើងទៅតាចាប់ហើយ ។ ម៉េចបានគេឡើងមកដល់មុនយើងទៅក្រោយ ព្រោះឡើងវាខុស ខាងតាខៀវគាត់នៅអានសេះ នៅខាងទន្លេល្ពៅ នៅ១០០១ ដល់យើងឡើងមកវាចំយួនស្មាក់លិចកើត គេចចូលច្រក១០០៣ ដល់អ៊ីចឹងអត់ហ៊ានឡើង ចាក់មកភ្នំឆ័ត្រនេះ ។

ដានីៈ កាលហ្នឹងកងទ័ពច្រើនអត់ដែលចាក់មកហ្នឹង?

វើតៈ កាលខ្ញុំមក៦០០នាក់ ។

ដានីៈ កងពល១១៧ហ្នឹង?

វើតៈ ១១៧មកជាមួយភាគកណ្ដាលខ្លះទៀត មកបេះតែនាំគ្នាមក គាត់ឲ្យនៅចាំកន្លែងភ្នំជីកំពង់ធំយើងហ្នឹង នៅចាំកន្លែងមួយៗ ម៉ាកន្លែង៧-៨នាក់, ១០-២០នាក់ ។

ដានីៈ អ៊ីចឹងក៏ចាក់មកខាងភ្នំឆ័ត្រវិញ?

វើតៈ ចាក់មកភ្នំឆ័ត្រ ។

ដានី:	ជួបជាមួយ តាយន?

វើត:	ជួបបងយន ដល់នៅជាមួយគាត់បានប៉ុន្មានថ្ងៃ។ បងយន ក៏គាត់ស្គាល់ពូខ្ញុំហ្នឹងដែលឈ្មោះចិន វរសេនាធំជាមួយគ្នាហ្នឹង ដល់អីចឹង គាត់ថាអើទៅក៏ទៅ ខ្ញុំជិះឡានដឹកគ្រាប់មក ។

ដានី:	ចុះកងទ័ព៦០០នាក់ទៀត?

វើត:	ហ្នឹងនៅជាមួយបងយនហ្នឹង ផ្ញើទ័ពហ្នឹងវិញទៅ ការប្រពន្ធ ខ្លះក៏ឈប់ផ្ញើទ័ពអីចឹងទៅ នៅខាងប្រជាជនទៅ ។

ដានី:	ចុះ៦០០នាក់ហ្នឹងមិនមែនទៅខាងប៉ៃលិនជាមួយ...?

វើត:	អត់ទេ! ខាងប៉ៃលិនវត់មកផ្សេង ។

ដានី:	អីចឹងបានន័យថាកងទ័ពវា...?

វើត:	បែកជា៣-៤ ។

ដានី:	បែកជា៣-៤ អីចឹងនៅប៉ៃលិននៅមួយចំនួនដែរទេ មិនមែនមានទាំងអស់ទេ?

វើត:	ប៉ៃលិនមកប្រហែលជាខ្ទង់៦០០-៧០០ដែរ តែខាងប៉ៃលិនកំលាំងគេសុទ្ធពីនោះ ដល់ពួកខ្ញុំនេះចំរុះ ខាងកាត់ដេរផង ខាងមន្ទីរពេទ្យមកជាមួយខ្ញុំ កំលាំងពេទ្យ ហើយនិងកំលាំងចំរុះភាគកណ្តាលមកពីត្រើយកើតមកជាមួយគ្នា ។

ដានី:	ដល់ក្រោយៗមកមានដែលជួបខាងតាមុត អត់? តាមុត គាត់ទៅខាងសំឡូតទៅ?

វើត:	អត់ដែលជួបគាត់ អត់រហូត បើពូរ៉ែន ជួបគាត់មក ឆ្នាំ៨២គាត់មកនេះ ខ្ញុំជួប...។

ដានី:	តារ៉ែន គាត់មកហ្នឹង គាត់ជា...?

វើត:	គាត់មកអគ្គ ដូចថាគាត់អគ្គតំរួតយោធាជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យមុនហ្នឹងហើយ គាត់អ្នកត្រួតសមរភូមិទាំងអស់ ឲ្យតែកន្លែងណាតឹងតែងគាត់ទៅវើទាំងអស់ ។

ដានី:	កាលពីមុនកាលគាត់នៅតាកែវ គាត់ប្រធានកងពលទី២ទេ?

វើត:	គាត់ប្រធានកងពល ដល់គាត់ទៅនៅកន្លែរដ្ឋ នៅកន្លែងនោះដូចថាគាត់ក្បាលម៉ាស៊ីន គាត់អ្នកហ៊ាន ខាងលើត្រូវចាត់តាំងឲ្យគាត់ត្រួតរួម ដោយឡែកគាត់ដឹកពេក ស្រី ។

ដានី:	ប៉ុន្តែបន្ទាប់ពីកងពលទី២សម័យឆ្នាំ៧៥-៧៩ គាត់នៅតែប្រធានកងពលទី២ ឬក៏មានឡើងអីទៀត?

វើត:	អត់ទេ! ប្រធានកងពលរហូត ។

ដានី:	រហូតដល់បែក?

វ៉ែតៈ គាត់មកឡើងធំនឹងបែក៧៩ហើយ គាត់អ្នករំដោះរដ្ឋ អ្នកដឹកនាំធំៗហ្នឹង ។

ដានីៈ គាត់ធំជាងគណៈសមរភូមិទៀត?

វ៉ែតៈ គាត់ធំជាង គាត់គ្រួត តាមុត ក៏អត់ហ៊ានជាមួយគាត់ដែរ ។ ដល់អស់ពីពូវ៉ែន បាន តាមុត កាន់ៗ ដល់ពូវ៉ែន គាត់ឆ្អួត ដល់គាត់ឈឺ ខ្ញុំទៅលេងជាមួយគាត់៨៨ ខ្ញុំទៅលេងគាត់ ដេកខ្វិន ហូរទឹកភ្នែក ឃើញខ្ញុំហូរទឹកភ្នែក ។

ដានីៈ លោកពូគ្រួសារលោកពូឈ្មោះអីទៅ? ខ្ញុំអត់បានសួរម៉ិញ? ប្រពន្ធលោកពូ?

វ៉ែតៈ ប្រពន្ធរាល់ថ្ងៃនេះ?

ដានីៈ លោកពូមានប្រពន្ធ២អីចឹង?

វ៉ែតៈ វានិយាយមិនកើត ។ មើលក្នុងប្រវត្តិរូបនេះវិញបណ្តោយ ។

ដានីៈ លោកពូស្គាល់ហើយចាំបាច់ខ្ញុំមើល នាំពីបាក នាំតែខាត ។ ប្រពន្ធឈ្មោះអី?

វ៉ែតៈ ក្នុងអត្តសញ្ញាណបណ្ណសញ្ញាតិខ្មែរ ដាក់ ដុន ទូច ។

ដានីៈ ប្រពន្ធ ។

វ៉ែតៈ បើជាប់គុកជាប់ទាំងអស់គ្នា ។

ដានីៈ ប្រពន្ធដើមលោកពូឈ្មោះអីទៅ?

វ៉ែតៈ ប្រាក់ យុទ្ធ ហ្នឹង ។

ដានីៈ ប្រាក់ យុទ្ធ ប្រពន្ធដើមលោកពូ ។ លោកពូមានកូនចៅប៉ុន្មាននាក់ដែរ?

វ៉ែតៈ ខ្ញុំកូន៤ ។

ដានីៈ ទាំងអស់៤នាក់? ប្រពន្ធក្រោយមានកូនប៉ុន្មាន?

វ៉ែតៈ ប្រពន្ធក្រោយមួយ, ប្រពន្ធមុនមួយ ហើយអាកណ្តាលនោះ២ ។

ដានីៈ អីចឹងប្រពន្ធ៣ហើយ?

វ៉ែតៈ និយាយមិនកើតទេ ។

ដានីៈ លោកពូគ្រាន់បើអីចឹង ។ ហើយសព្វថ្ងៃលោកពូនៅភូមិអី?

វ៉ែតៈ ភូមិហ្នឹងជាមួយគ្នា ភូមិទួលចក្រី ។

ដានីៈ ភូមិទួល ឃុំបារាំងធ្លាក់ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ។

វ៉ែតៈ បាទ!

ដានីៈ បាទ! អីចឹងខ្ញុំអរគុណលោកពូច្រើន បានផ្តល់ដូចជាចែករំលែកបទពិសោធន៍ដែលពូធ្លាប់ដឹង ដល់ពួកខ្ញុំ ខ្ញុំអរគុណលោកពូច្រើន ។

ចប់